N°44/15→15/6/2015

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២២-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៩៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់លោក **រ៉ូប៊ឺត ជោហ្សេហ្វ ផូម៉ាយស៍** (Robert Joseph Pomice) ជនជាតិអាមេរិក សញ្ជាតិអាមេរិក ៤៩៨៥

២២-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៩៧ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម ចំនួន ០៣ រូប នូវគ្រឿងឥស្សរិយយស ជាតូបការ ៤៩៨៦

២២-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៩៨ ស្តីពី ការតែងតាំងឯកឧត្តម ៣ រូប ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៤៩៨៧

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៩៩ ស្តីពី ការតែងតាំងឯកឧត្តម **គ្រី ចំរើន** ជាទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៤៩៨៨

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៥០០ ស្តីពី ការតែងតាំងជាទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៤៩៨៩

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៥០១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមនាវីទោ ដល់ឧត្តមនាវីត្រី **ទៀ ប៊ុនលៀម** នាយទាហានថ្នាក់ឧត្តមនាវី នៃកងយោធពលខេមរភូមិន្ទ ៤៩៩០

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៥០២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់វរសេនីយ៍ឯក **គន្ធ ប៊ុនធឿន** នាយទាហានថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៤៩៩១

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៥០៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់លោក **ចាង អ៊ី** (ZHANG YI) ជនជាតិចិន សញ្ជាតិចិន ៤៩៩២

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៥០៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់លោក **ចាង វៃជុន** (ZHANG WEIJUN) ជនជាតិចិន សញ្ជាតិចិន ៤៩៩៣

២៣-៥-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៥០៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់លោក **ប៉ូណូម៉ារ៉េវ សឺហ្គេ** (PONOMAREV SERGEY) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី ៤៩៩៤

០៨-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦០៥ ស្តីពី ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យសព សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា ចំនួន ២៧ រូប ៤៩៩៥

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

០៨-៦-២០១៥ -អនុក្រឹត្យលេខ ៧៤ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ និងមាត្រា ២៩ និងបំពេញបន្ថែមមាត្រា ២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៤៩៩៨

០៩-៦-២០១៥ -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥០០៣

*-អនុក្រឹត្យលេខ ៧៦ អនក្រ.បក មិនទាន់បានទទួល*

០៩-៦-២០១៥ -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្តីពី ការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំពិធីបុណ្យសពសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ៥០០៥

២៨-៥-២០១៥ -អនុក្រឹត្យលេខ ៥៩៥ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥០១០

២៨-៥-២០១៥ -អនុក្រឹត្យលេខ ៥៩៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥០១២

២៨-៥-២០១៥ -អនុក្រឹត្យលេខ ៥៩៧ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៥០១៣

២៩-៥-២០១៥ -អនុក្រឹត្យលេខ ៥៩៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥០១៤

២៩-៥-២០១៥ -អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥០១៦

២៩-៥-២០១៥ -អនុក្រឹត្យលេខ ៦០០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ ៥០២០

២៩-៥-២០១៥ -អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីនគរបាលជាតិ ៥០២១

២៩-៥-២០១៥ -អនុក្រឹត្យលេខ ៦០២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥០២២

## ២-សេចក្តីសម្រេច

០៥-៦-២០១៥ -សេចក្តីសម្រេចលេខ ៤០ សសរ ស្តីពី ការបង្កើតអនុគណៈកម្មាធិការនៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនគោក កម្ពុជា-ថៃ ៥០២៣

០៥-៦-២០១៥ -សេចក្តីសម្រេចលេខ ៤១ សសរ ស្តីពី ការតែងតាំងសមាសភាពនៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ៥០២៦

១០-៦-២០១៥ -សេចក្តីសម្រេចលេខ ៤២ សសរ ស្តីពី ការតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៥០២៨

១០-៦-២០១៥ -សេចក្តីសម្រេចលេខ ៤៣ សសរ ស្តីពី ការតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ៥០៣០

១០-៦-២០១៥ -សេចក្តីសម្រេចលេខ ៤៤ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងស៊ើបអង្កេតពិសេស លើករណីបណ្តឹងលេខ ២៣១៨ ស្តីពី ករណីឃាតកម្មលើមេដឹកនាំសហជីព **ជា វិជ្ជា ហ៊ី វុទ្ធី** និង **រស់ សុវណ្ណារ៉េត** ៥០៣២

## ៣-សារាចរណែនាំ

០៥-៦-២០១៥ -សារាចរណែនាំលេខ ០៥ សរណន ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ៥០៣៤

០៨-៦-២០១៥ -សារាចរណែនាំលេខ ០៦ សរណន ស្តីពី ការប្រារព្ធពិធីកាន់ទុក្ខ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា ៥០៥៦

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៥-៥-២០១៥ -ប្រកាសអន្តរក្រសួងលេខ ៥២៦ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៥ របស់ក្រសួងការពារជាតិ ៥០៥៧

០៧-៥-២០១៥ -ប្រកាសលេខ ៥៣៣ សហវ.ប្រក ស្តីពី ប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់មន្ត្រីនៃលក្ខន្តិកៈ របស់គណៈកម្មការមូលបត្រកម្ពុជា ៥០៦១

## ២.ធនាគារជាតិ នៃ កម្ពុជា

២៩-៥-២០១៥ -ប្រកាសលេខ ធ៥.០១៥.១៨៨ ប្រក ស្តីពី ការបង្កើតមណ្ឌលដោះដូរមូលប្បទានបត្រនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង ៥០៦៤

២៩-៥-២០១៥ -ប្រកាសលេខ ធ៥.០១៥.១៨៩ ប្រក ស្តីពី ការបង្កើតមណ្ឌលដោះដូរមូលប្បទានបត្រនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ ៥០៦៦

## ៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-៦-២០១៥ -ប្រកាសលេខ ១៤២ ពណ.ចបព.ប្រក ស្តីពី បែបបទ និងនីតិវិធី ចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ៥០៦៨

## ៤.ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២៩-៥-២០១៥ -សេចក្តីណែនាំលេខ ០១ កយ.សណន/១៥ ស្តីពី និរន្តរភាព ប្រសិទ្ធភាព និងសុខដុមនីយកម្ម នៃអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ៥០៧១

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៦៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **រ៉ូប៊ឺត ជោសែហ្វ ផូម៉ាយស៍** (RobertJoseph Pomice) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៣៨ នៅសហរដ្ឋអាមេរិក។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ. ១៥០៥.៥០២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៥*

លេខៈ ៥១១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

ចំពោះ

១- ឯកឧត្តម ម៉ឹន ឌុន្ធា

២- ឯកឧត្តម ឌៀប សុខុម

៣- ឯកឧត្តម ឈឹម ព្រះខ័ន

នូវ

**គ្រឿងឥស្សរិយយស ជាតូបការ**

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ពរល.១៥០៥.៥០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥

លេខៈ ៥១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដាឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង:

១- ឯកឧត្តម **ជា ពិសិដ្ឋ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២- ឯកឧត្តម **ហេង ប្រសិទ្ធ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ**។

៣- ឯកឧត្តម **សុខ សេរីបុត្រ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១៥០៥.៥០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥

លេខ: ៤៨៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៥**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៥១៥/៤៩៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **គ្រី ចំរើន** ជាទីប្រឹក្សាអមក្រសួងព័ត៌មាន មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១៥០៥.៥០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ: ៥៧២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៥០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងជាទីប្រឹក្សាក្រសួងមហាផ្ទៃចំនួន ០២ រូប :

១- ឯកឧត្តម **ជា សុធន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម **ណារ៉ា ណារ៉ាឌុង** មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១៥០៥.៥០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥*

លេខៈ ៥២៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៥០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១៖** តម្លើងឋានន្តរស័ក្តិ **ឧត្តមនាវីទោ** ដល់ ឧត្តមនាវីត្រី **ទៀ ម៉ុនលៀម** អត្តលេខ ០១៣៩៨៦ នាយទាហានថ្នាក់ឧត្តមនាវី នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២៖** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរណ.១៥០៥.៥០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥

លេខៈ ៥៧៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៥០២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់វរសេនីយ៍ឯក **គង្គ ម៉ិនធឿន** អត្តលេខ ០១០៩២៣ នាយទាហានថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥

ទាវលេ. ១៥០៥.៥០៤

លេខៈ ៥២៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៥០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ចាង អ៊ី** (ZHANG YI) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៦៩ នៅខេត្តលាវនីង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៥០៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៧នល.១៥០៥.៥០៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៥០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាង វៃជុន** (ZHANG WEIJUN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៦៩ នៅខេត្តគៀនជិន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចាង ហានលីន** (ZHANG HAN LIN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩ស.១៥០៥.៥១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ: ៥០៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៥០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ប៉ូណូម៉ារ៉េវ សឺហ្គេ** (PONOMAREV SERGEY) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៨៣ នៅទីក្រុងឃីមគី សហព័ន្ធរុស្ស៊ី។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពារស.១៥០៥.៥១១

លេខៈ ៥០៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី ៥ នៃរដ្ឋសភា នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យសព **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា | ប្រធាន |
| ២- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា | អនុប្រធាន |
| ៥- ឯកឧត្តម **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦- ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី២ រដ្ឋសភា | សមាជិក |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៧- ឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិក

៨- ឯកឧត្ដម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៩- ឯកឧត្ដម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក

១០- ឯកឧត្ដម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ សមាជិក

១១- ឯកឧត្ដម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិការអន្តរជាតិ សមាជិក

១២- លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអធិការកិច្ច និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា សមាជិកា

១៣- ឯកឧត្ដម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី សមាជិក

១៤- ឯកឧត្ដម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី សមាជិក

១៥- ឯកឧត្ដម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី សមាជិក

១៦- ឯកឧត្ដម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៧- ឯកឧត្ដម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន សមាជិក

១៨- ឯកឧត្ដម **មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា សមាជិក

១៩- ឯកឧត្ដម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

២០- ឯកឧត្ដម **នៃ ប៉េណា** សមាជិកព្រឹទ្ធសភា សមាជិក

២១- ឯកឧត្ដម **ស៊ឹម កា** សមាជិកព្រឹទ្ធសភា សមាជិក

២២- ឯកឧត្ដមនាយឧត្ដមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

២៣- ឯកឧត្ដមនាយឧត្ដមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

២៤- ឯកឧត្ដមនាយឧត្ដមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២៥- ឯកឧត្ដម **ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

២៦- អ្នកឧកញ៉ាភក្ដីព្រះស្ដេច **ហេង គឹមគុណ** សមាជិក

២៧- ឯកឧត្ដម **ឈិន កេតនា** អគ្គលេខាធិការ នៃគណៈកម្មាធិការបុណ្យជាតិ និងអន្តរជាតិ សមាជិក

**មាត្រា២ :** គណៈកម្មការនេះ មានភារកិច្ចរៀបចំពិធីបុណ្យសព **សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ឱ្យមានដំណើរការល្អប្រសើរ ឧត្ដុង្គឧត្ដម សក្ដិសមនឹងឋានៈ និងកិត្តិយសរបស់**សម្ដេច** ។

**មាត្រា៣ :** គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការនានាជាជំនួយការ តាមការចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤ :** សម្តេច ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស/រកត.១៥០៦.៦១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ៥៣៦ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី១៨ ខែមិថុនាឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ និងមាត្រា ២៩ និងបំពេញបន្ថែម មាត្រា ២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២/ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សម្រេច**

**មាត្រាមួយ._**

មាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ នៃអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបានកែសម្រួល និងមាត្រា ២៩ស្ទួន ត្រូវបានបំពេញបន្ថែមទៅក្នុងអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដូចតទៅ៖

**មាត្រា២៦ ថ្មី.-**

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការងារអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ និងនវានុវត្តន៍ លើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ តាមកម្មវិធីសិក្សា ដែលមានការយល់ព្រមពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា២៧ ថ្មី.-**

វិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានភារកិច្ចដូចតទៅ៖

- រៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេក-វិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំឱ្យមានការប្រឡងវាស់កម្រិតសមត្ថភាពជំនាញប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- លើកសំណើសុំចេញសញ្ញាបត្រ ឬវិញ្ញាបនបត្រទទួលស្គាល់កម្រិតសមត្ថភាពជំនាញលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ក៏ដូចវិស័យឯកជន ដើម្បីពង្រឹងការអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ស្រាវជ្រាវ និងធ្វើនវានុវត្តន៍លើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា២៨ ថ្មី.-**

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានលេខាធិការដ្ឋានចំណុះចំនួន ០១ (មួយ) មហាវិទ្យាល័យចំណុះចំនួន ០៣ (បី) មជ្ឈមណ្ឌលចំណុះចំនួន ០៣ (បី) និងសាលាចំណុះចំនួន ០១ (មួយ)៖

- លេខាធិការដ្ឋាន
- មហាវិទ្យាល័យគ្រប់គ្រងប្រៃសណីយ៍ និងភស្តុភារ
- មហាវិទ្យាល័យបច្ចេកវិទ្យាទូរគមនាគមន៍ និងបណ្តាញ
- មហាវិទ្យាល័យវិទ្យាសាស្ត្រកុំព្យូទ័រ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
- មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍
- មជ្ឈមណ្ឌលអប់រំពីចម្ងាយ, និង
- សាលាក្រោយបរិញ្ញាបត្រ។

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អាចពង្រីករចនាសម្ព័ន្ធ បង្កើតមហាវិទ្យាល័យ មជ្ឈមណ្ឌលស្រាវជ្រាវ ឬដេប៉ាតឺម៉ង់ថែមទៀតតាមការចាំបាច់ ដោយមានការយល់ព្រមពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា២៩ ថ្មី.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើបេសកកម្មគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់វិទ្យាស្ថាន។

មហាវិទ្យាល័យប្រៃសណីយ៍ និងភស្តុភារ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការអប់រំវិស័យប្រៃសណីយ៍ និងភស្តុភារ។

មហាវិទ្យាល័យបច្ចេកវិទ្យាទូរគមនាគមន៍ និងបណ្តាញ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការអប់រំវិស័យទូរគមនាគមន៍ និងបណ្តាញ។

មហាវិទ្យាល័យវិទ្យាសាស្ត្រកុំព្យូទ័រ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការអប់រំវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការស្រាវជ្រាវ និងនវានុវត្តន៍ លើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

មជ្ឈមណ្ឌលអប់រំពីចម្ងាយ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការអប់រំពីចម្ងាយ លើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

សាលាក្រោយបរិញ្ញាបត្រ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការអប់រំថ្នាក់ក្រោយបរិញ្ញាបត្រវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**មាត្រា២៩ ស្ទួន.-**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងលេខាធិការដ្ឋាន មហាវិទ្យាល័យនីមួយៗ សាលាក្រោយបរិញ្ញាបត្រ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ មជ្ឈមណ្ឌលអប់រំពីចម្ងាយ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

លេខាធិការដ្ឋាន សាលាក្រោយបរិញ្ញាបត្រ ត្រូវដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនតាមការចាំបាច់។

មហាវិទ្យាល័យនីមួយៗ ត្រូវដឹកនាំដោយព្រឹទ្ធបុរសមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងព្រឹទ្ធបុរសរងមួយចំនួនតាមការចាំបាច់។

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ និងមជ្ឈមណ្ឌលអប់រំពីចម្ងាយ ត្រូវដឹកនាំដោយ ប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រាពីរ.-**

អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបានកែសម្រួលដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រាបី.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបួន.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបួន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៧៤...អនក្រ.បក
ចុះថ្ងៃទី...០៨...ខែ...មិថុនា...ឆ្នាំ២០១៥
ឧបសម្ព័ន្ធថ្មីនៃអនុក្រឹត្យលេខ៣៩ អនក្រ.បក
ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..៩៧៥...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ១៩០៤ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន៤០៧ ២០០ ០០០រៀល (បួនរយប្រាំពីរលាន ពីររយពាន់រៀលគត់) ពីជំពូក៦០ (ការទិញ) មកជំពូក៦១ (សេវាកម្ម) ជូនក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៦៧...អនក្រ.បក

ជាតិ សាសនា ព្រះមហាក្សត្រ

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំពិធីបុណ្យសព សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយស ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ០៦១៥/រកត/៦០៥ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈ-កម្មការរៀបចំពិធីបុណ្យសពសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា
- យោងសំណូមពរការងារ និងតម្រូវការចាំបាច់

## សម្រេច

**មាត្រា ១.-**

បានបង្កើតអនុគណៈកម្មការជាជំនួយការទទួលបន្ទុកអនុវត្តការងាររបស់គណៈកម្មការរៀបចំពិធីបុណ្យសព សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា មានសមាសភាពដូចខាងក្រោមៈ

ក-អនុគណៈកម្មការបដិសណ្ឋារកិច្ច និងពិធីការ

១-ឯកឧត្តម **ឈិន កេតនា** ប្រធាន

២-ឯកឧត្តម **ណូ សម្បុរ** សមាជិក

៣-ឯកឧត្តម **ដួង អេលីត** សមាជិក

៤-ឯកឧត្តម **ឈឹម សុខគុណ** សមាជិក

៥-ឯកឧត្តម **ព្រហ្ម ធីរៈ** សមាជិក

៦-ឯកឧត្តម **ហ៊ីម សុធារិទ្ធ** សមាជិក

៧-ឯកឧត្តម **ប៊ុន សេរី** សមាជិក

៨-លោក **ប្រាក់ ខូនហុង** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ច ៖

- ធ្វើបដិសណ្ឋារកិច្ចទទួលភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ដែលត្រូវចូលរួមក្នុងពិធីបុណ្យសព
- រៀបចំលិខិតស្នាមផ្សេងៗទាក់ទងជាមួយបណ្តាប្រទេស បណ្តាទូត និងអង្គការអន្តរជាតិនានា
- រៀបចំពិធីគោរពសពតាមកម្មវិធីដែលបានកំណត់
- អញ្ជើញភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ចូលរួមក្នុងពិធីបុណ្យសព និងពិធីបូជាសព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

ខ-អនុគណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ

១-ឯកឧត្តម **ខៀវ កាញារីទ្ធ** ប្រធាន

២-ឯកឧត្តម **ម៉ៅ អាយុទ្ធ** សមាជិក

៣-ឯកឧត្តម **ស្វាយ ស៊ីថា** សមាជិក

៤-ឯកឧត្តម **គីម គុណវឌ្ឍន៍** សមាជិក

៥-ឯកឧត្តម **និត សុធា** សមាជិក

៦-លោក **ឡុង ឌីម៉ង់** សមាជិក

អនុគណៈកម្មការនេះមានភារកិច្ច ៖

- ធ្វើការផ្សាយព័ត៌មាន រូបភាព តាមវិទ្យុ ទូរទស្សន៍ជាតិ និងប្រព័ន្ធផ្សព្វផ្សាយនានាអំពីពិធីបុណ្យសព
- វិឃោគកថា និងឯកសារពាក់ព័ន្ធពិធីបុណ្យ
- រថយន្តមីក្រូ ឧបករណ៍សំឡេងសម្រាប់ពិធីតាមតម្រូវការ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

គ-អនុគណៈកម្មការស្ថាបនាមេរុ រថយន្តបុស្បុក ក្បួនដង្ហែ និងពិធីសាសនា

១- សម្តេចចៅហ្វាវាំង **គង់ សំអុល** ប្រធាន

២- ឯកឧត្តម **គុយ សុផល** សមាជិក

៣- ឯកឧត្តម **មិន ឃិន** សមាជិក

៤- ឯកឧត្តម **ឃឹម សារិទ្ធ** សមាជិក

៥- ឯកឧត្តម **ឌិា សុជាតិវង្ស** សមាជិក

៦- ឯកឧត្តម **ឥត សារ៉ាត់** សមាជិក

៧- អ្នកឧកញ៉ាភក្តីព្រះសម្តេច **ហេង គីមគុណា** សមាជិក

៨- ឯកឧត្តម **ឃី ឆន់** សមាជិក

៩- ឯកឧត្តម **កែវ រតនៈ** សមាជិក

១០- ឯកឧត្តម **ស៊ឹម ស៊ីថា** សមាជិក

១១-លោកជំទាវ **ម៉ក់ វណ្ណស៊ីថា** សមាជិកា

អនុគណៈកម្មការនេះ មានភារកិច្ចៈ

- រៀបចំតម្លើងមេរុនៅទីតាំងដែលបានកំណត់ឲ្យបានទាន់ពេលវេលា ដោយត្រូវរៀបចំឲ្យបានស្របទៅនឹងប្រពៃណី រក្សារចនាបថខ្មែរ
- រៀបចំរថយន្តបុស្បុកសម្រាប់ដង្ហែ តាមចំនួនកំណត់សម្រាប់បម្រើពិធីដង្ហែសព
- រៀបចំពន្លា វេទិកា និងរោងមហាជន តុបតែងលម្អតាមតម្រូវការចាំបាច់
- ធ្វើកម្មវិធីលម្អិត សម្រាប់បម្រើការរៀបចំបុណ្យសព ពីធីដង្ហែសព និងពិធីបូជាសព
- ទំនាក់ទំនងក្នុងការនិមន្តព្រះសង្ឃ ចូលរួមទទួលភត្ត បង្សុកូល ចម្រើនព្រះបរិត្ត ទេសនា សូត្រព្រះធម្ម
- ត្រៀមលក្ខណៈរៀបចំទេយ្យទាន សម្ភារៈ បរិក្ខារ សម្រាប់បម្រើកិច្ចការសាសនា តាមតម្រូវការ
- រៀបចំក្បួនដង្ហែសព ប្លង់ដង្ហែតាមមហាវិថីនានាឆ្លងកាត់ រូបភាពចាត់តាំងក្បួន តាមប្រពៃណី
- ផ្តល់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានស្ថេរភាពបម្រើឲ្យពិធី
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

ឃ-<u>អនុគណៈកម្មការការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ និងសង្គ្រោះបន្ទាន់</u>

១- ឯកឧត្តម **នេត សាវឿន** ប្រធាន

២-ឯកឧត្តម **យូ ស៊ុនឡុង** សមាជិក

៣- ឯកឧត្តម **តែ គុយស៊ាង** សមាជិក

៤- ឯកឧត្តម **សៅ សុខា** សមាជិក

៥-ឯកឧត្តម **ហេង រតនា** សមាជិក

៦-ឯកឧត្តម **ឃួង ស្រេង** សមាជិក

៧-ឯកឧត្តម **ខួច ណារ៉ុង** សមាជិក

៨-ឯកឧត្តម **ជួន សុវណ្ណា** សមាជិក

៩-ឯកឧត្តម **រ័ត្ន ស្រ៊ាង** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចៈ

- រក្សាការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ សុខមាលភាព ឲ្យធានាសុវត្ថិភាពក្នុងពេលប្រារព្ធពិធីបុណ្យសព រហូតដល់ថ្ងៃបញ្ចប់ពិធីបូជាសព
- ត្រៀមលក្ខណៈចាត់តាំងគ្រូពេទ្យ ថ្នាំពេទ្យ និងរថយន្តសង្គ្រោះសម្រាប់សង្គ្រោះបន្ទាន់ អ្នកមកចូលរួមពិធីបុណ្យសពរាល់ថ្ងៃ ពិធីដង្ហែ តម្កល់ និងបូជាសព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

ង-<u>អនុគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ និងជីវភាព</u>

១-ឯកឧត្តម **ជុំ គឹមឡេង** ប្រធាន

២-ឯកឧត្តម **ឈិន កេតនា** សមាជិក

៣-ឯកឧត្តម **ប៊ូន លីមហេង** សមាជិក

៤-ឯកឧត្តម **ម៉ែន ឧុទ្ធី** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ច ៖

- លើកគម្រោងសម្ភារ ថវិកា ដែលត្រូវចំណាយសម្រាប់បម្រើការរៀបចំពិធី ដើម្បីសុំយោបល់សម្រេចពីគណៈ-កម្មការរៀបចំពិធីបុណ្យសព
- ដោះស្រាយសម្ភារ ថវិកាបម្រើការរៀបចំពិធីបុណ្យសព ចាប់ពីថ្ងៃទទួលមរណភាពរហូតដល់ថ្ងៃដង្ហែ និងពិធីបូជាសព
- គ្រប់គ្រង និងប្រើប្រាស់សម្ភារ ថវិកាឲ្យបានឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្តែងនៃការរៀបចំពិធីបុណ្យសព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

**មាត្រា ២.-**

អនុគណៈកម្មការនីមួយៗមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមតម្រូវការចាំបាច់។

**មាត្រា ៣.-**

ការចំណាយលើការងារផ្សេងៗរបស់អនុគណៈកម្មការនីមួយៗ ត្រូវដាក់ឆ្លងអនុគណៈកម្មការហិរញ្ញវត្ថុ និង **សម្តេចចៅហ្វាវាំង គង់ សំអុល** អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការ ពិនិត្យ និងសម្រេច ដោយប្រើប្រាស់ក្រាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ។ ក្នុងករណីមិនអាចសម្រេចបាន ត្រូវស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងជាអនុប្រធាននៃគណៈកម្មការ ពិនិត្យ និងសម្រេច។

**មាត្រា ៤.-**

អនុគណៈកម្មការនីមួយៗត្រូវប្តូកសរុបរាយការណ៍ ការងាយស្រួល ការលំបាក សំណូមពរជូន**សម្តេចចៅហ្វាវាំង** អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការ ដើម្បីពិនិត្យ ដោះស្រាយ និងផ្តល់យោបល់ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ពិនិត្យ សម្រេច។

**មាត្រា ៥.-**

សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដូចក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពខ្ពស់។

**មាត្រា ៦.-**

អនុក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៥៩៥.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** សម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការចំនួន ០៨ រូប របស់ក្រសួងទេសចរណ៍ ដូចមានរាយនាមខាងក្រោម ៖

ក/ ទីប្រឹក្សាក្រសួងទេសចរណ៍

១- លោក **ទែន រតនា** សម្រួលភារកិច្ចពីប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល ទៅជាទីប្រឹក្សាក្រសួង មានឋានៈស្មើប្រធាននាយកដ្ឋាន

**ខ/ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

១- លោក **គឹម សេរីរដ្ឋ** ជាប្រធានផ្នែកបច្ចេកទេសវាយតម្លៃទីក្រុងស្អាត មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោក **ច្រឡឹង សុមេធា** ជាប្រធានផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

៣- លោក **ហ៊ួត រិទ្ធី** ជាប្រធានផ្នែកសហប្រតិបត្តិការ និងផ្សព្វផ្សាយ មានឋានៈស្មើប្រធាននាយកដ្ឋាន

៤- លោក **លន់ ម៉ុនធឿន** ជាប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

**គ/ អគ្គនាយកដ្ឋានទេសចរណ៍**

១- លោក **ឡោ សុវិជ្ជា** សម្រួលភារកិច្ចពីអធិការ ទៅជាអគ្គនាយករងទេសចរណ៍ ជំនួសលោក **ចិន សាម៉ន** ដែលបានចូលនិវត្តន៍

**ឃ/ នាយកដ្ឋានអប់រំបណ្តុះបណ្តាល**

១- លោក **ឈឹម សុខជិន** ជាប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល ជំនួសលោក **ទែន រតនា** ដែលបានសម្រួលភារកិច្ចថ្មី

**ង/ អគ្គាធិការដ្ឋាន**

១- លោក **សំ ឧុទ្ធា** ជាអធិការ នៃអគ្គាធិការដ្ឋាន ជំនួសលោក **ឡោ សុវិជ្ជា** ដែលបានសម្រួលភារកិច្ចថ្មី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៩៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ** ចំនួន ០៤គ្រឿង ជូនមន្ត្រីរាជការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកែបចំនួន ០៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | **ជិន ឧុទ្ធី** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប |
| ២- | លោក | **ម៉ែន ហន** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប |
| ៣- | លោក | **ហ៊ូ ផល្លាវ៉ាទី** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប |
| ៤- | លោក | **សេក ដារិន** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៥៩៦៧..អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការផ្ទេរក្របខ័ណ្ឌ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាននៃកងយោធពលខេមរភូមិន្ទ ជូនវរសេនីយ៍ឯក **ព្រំ ចាន់ណា** អត្តលេខ០០៤៩០២ មេបញ្ជាការរង កងរាជអាវុធហត្ថខេត្តកណ្តាល បច្ចុប្បន្នទៅបម្រើ ការងារក្នុងក្របខ័ណ្ឌ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..៥៨៧..អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយសហមេត្រី**
**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ចំនួន ១៧គ្រឿង ជូនអង្គភាព ចំនួន ០៤ និងនាយទាហាន នៃកងទ័ពប្រជាជនវៀតណាម ចំនួន ១៣រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ ដោយជួយជួសជុល រថក្រោះ រថពាសដែកជូនបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

**-ចំពោះអង្គភាព**

១- សាលា៦០០ បណ្តុះបណ្តាលនាយទាហានរថក្រោះ រថពាសដែក នៃកងទ័ពប្រជាជនវៀតណាម
២- សាលា៧០០ បណ្តុះបណ្តាលអ្នកឯកទេសប្រើប្រាស់រថក្រោះ រថពាសដែក នៃកងទ័ពប្រជាជនវៀតណាម
៣- ស្នងការបច្ចេកទេសយោធភូមិភាគទី៧ នៃកងទ័ពប្រជាជនវៀតណាម
៤- ស្នងការបច្ចេកទេសយោធភូមិភាគទី៩ នៃកងទ័ពប្រជាជនវៀតណាម

**-ចំពោះបុគ្គល**

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ឯក | HA TUAN QUAN | អនុប្រធានស្នងការ យោធភូមិភាគទី៩នៃកងទ័ពប្រជាជនវៀតណាម |
| ២- | វរសេនីយ៍ឯក | VO VAN SAU | នាយករោងជាងជួសជុល ស្នងការបច្ចេកទេសយោធភូមិភាគទី៩ នៃកងទ័ពប្រជាជនវៀតណាម |
| ៣- | វរសេនីយ៍ឯកបំរ៉ុង | NGUYEN VAN KEN | នាយករងរោងជាងជួសជុល ស្នងការបច្ចេកទេសយោធភូមិភាគទី៩ នៃកងទ័ពប្រជាជនវៀតណាម |
| ៤- | វរសេនីយ៍ត្រី | NGUYEN VAN SUOL | បើកបរ ស្នងការបច្ចេកទេសយោធភូមិភាគទី៩ នៃកងទ័ពប្រជាជនវៀតណាម |

**ខ-មេដាយសមាមេត្រី ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១- | វរសេនីយ៍ទោ | TRUONG QUANG HOA | ប្រធានក្រុមជួសជុលយោធភូមិភាគទី៩ |
| ២- | អនុសេនីយ៍ឯក | PHAM CONG BINH | អនុប្រធានក្រុមជួសជុល យោធភូមិភាគទី៩ |
| ៣- | អនុសេនីយ៍ឯកបំរ៉ង | BUI VAN KHOI | ជាងជួសជុលម៉ាស៊ីនរថគ្រោះ យោធភូមិភាគទី៩ |
| ៤- | អនុសេនីយ៍ត្រី | NGUYEN MAN THUAT | ជាងជួសជុលម៉ាស៊ីនរថគ្រោះ យោធភូមិភាគទី៩ |
| ៥- | អនុសេនីយ៍ឯក | NGUYEN DUC THUAN | ជាងម៉ាស៊ីនរថគ្រោះ យោធភូមិភាគទី៩ |
| ៦- | អនុសេនីយ៍ត្រី | LE TUYET CUONG | ជាងជួសជុលអាវុធ យោធភូមិភាគទី៩ |
| ៧- | អនុសេនីយ៍ទោ | NGUYEN VAN MEN | ជាងគោនបាញ់ថ្នាំ យោធភូមិភាគទី៩ |
| ៨- | អនុសេនីយ៍ទោ | TANG VAN DAN | ជាងជួសជុលអាវុធ យោធភូមិភាគទី៩ |
| ៩- | ពលបាលទោ | TRAN VAN GIANG | ពេទ្យ យោធភូមិភាគទី៩ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៩៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមាសការងារ** តាមលំដាប់ថ្នាក់ ចំនួន ៥១គ្រឿង ជូននាយទាហាន និងនាយទាហានរង ចំណុះតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង ចំនួន ៥១រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ឯក | ផាន់ | សារ៉ា | អត្តលេខ ០៩០៨០៩ នាយរងការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២ | អនុសេនីយ៍ទោ | ច្រាន្ត | ម៉េង | អត្តលេខ ០៥៦៧៨២ មេបញ្ជាការ ខស៊ើបការ ការពារ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៣ | អនុសេនីយ៍ទោ | សម | ព្រឿង | អត្តលេខ ០៩១៨៤៩ ជំនួយការបរិក្ខា ការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៤ | អនុសេនីយ៍ទោ | គឹម | ចាន់ដារ៉ា | អត្តលេខ ០៥៦៨០៣ ជំនួយការ ការិយាល័យបច្ចេកទេស តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៥ | អនុសេនីយ៍ទោ | ម៉ៅ | ធឿន | អត្តលេខ០៥៦៨១០ ជំនួយការ ការិយាល័យអភិវឌ្ឍន៍ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៦ | អនុសេនីយ៍ត្រី | យឹម | យឹម | អត្តលេខ ០៥៦៨៣០ ជំនួយការ គោលនយោបាយ ការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៧ | អនុសេនីយ៍ត្រី | ឈិត | ច័ន្ទសុខា | អត្តលេខ ០៥៦៩១០ ជំនួយការ ឯកសារ ការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៨ | អនុសេនីយ៍ត្រី | ខេន | សុខុម | អត្តលេខ ១០២៤១៥ ជំនួយការ ប្រតិបត្តិការ ការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

| | | | | |
|---|---|---|---|---|
| ៩ | អនុសេនីយ៍ត្រី | **លឹម** | **សុនហាច** | អត្តលេខ ០៥៦៨៨៣ ជំនួយការ ហិរញ្ញវត្ថុ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១០ | អនុសេនីយ៍ត្រី | **គ្រោះ** | **មន** | អត្តលេខ ១១៣៤០៥ ជំនួយការ ចិត្តសាស្ត្រ ផ្នែកសឹករងសាមគ្គីមានជ័យ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១១ | អនុសេនីយ៍ត្រី | **ហ៊ឹម** | **ហេង** | អត្តលេខ ០៥៦៩២៩ ជំនួយការ ប្រតិបត្តិការ ផ្នែកសឹករងសាមគ្គីមានជ័យ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១២ | អនុសេនីយ៍ត្រី | **ខៀវ** | **លី** | អត្តលេខ ០៥៦៨១៣ មេបញ្ជាការរង កងអនុសេនាធំលេខ២ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៣ | អនុសេនីយ៍ត្រី | **ឆេង** | **ខៀវ** | អត្តលេខ ០៥៦៧៨៤ មេបញ្ជាការរង កងអនុសេនាធំលេខ៣ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៤ | នាយចំណង់ | **ហាន** | **ស៊ីម** | អត្តលេខ ០៩១៧១៣ ជំនួយការ បូកសរុប ការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

**ខ-មេដាយត្រាក់ការងារ**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ត្រី | **ចាន់** | **សំអាត** | អត្តលេខ ០៨៥០៥៥ ជំនួយការ ហ្វឹកហ្វឺន ផ្នែកសឹករងកំពង់លែង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២ | អនុសេនីយ៍ត្រី | **ញ៉ិល** | **ឌុន្ធីន** | អត្តលេខ ០៩១៨៨៣ ជំនួយការ ប្រតិបត្តិការ ផ្នែកសឹករងក្រុងកំពង់ឆ្នាំង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៣ | អនុសេនីយ៍ត្រី | **ជុំ** | **ឆេងហៀង** | អត្តលេខ ០៨៤៩១០ ជំនួយការ ការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៤ | អនុសេនីយ៍ត្រី | **អ៊ុក** | **សារិន** | អត្តលេខ ១៣៩០២២ ជំនួយការ ការយាល័យហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៥ | អនុសេនីយ៍ត្រី | **សៅ** | **ម៉ន្ធសុភ័ក្រ** | អត្តលេខ ០៨៨៨០០ ជំនួយការ លិខិតស្នាម លេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៦ | អនុសេនីយ៍ត្រី | **ឈិច** | **ញ៉ិច** | អត្តលេខ ០៨៤៩៩៧ មេបញ្ជាការរង កងអនុសេនាធំលេខ១ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៧ | នាយចំណង់ | **អ៊ុំ** | **សុគា** | អត្តលេខ ១៣៩០០៧ មេបញ្ជាការរង កងអនុសេនាតូចស៊ើបការណ៍ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៨ | នាយចំណង់ | **ឈុំ** | **ដារ៉ា** | អត្តលេខ ០៩១៨៦៣ ជំនួយការ ការិយាល័យហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៩ | នាយចំណង់ | **ឈន** | **សំណាង** | អត្តលេខ ១៣៩០៣៣ ជំនួយការ ការិយាល័យបច្ចេកទេស តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១០ | នាយចំណង់ | **គី** | **ប្រុញ** | អត្តលេខ ១១៣២៨៥ ជំនួយការហ្វឹកហ្វឺន ផ្នែកសឹករងកំពង់ត្រឡាច តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១១ | នាយចំណង់ | **ខុ** | **កុសល** | អត្តលេខ ១៣៣២៤៨ ជំនួយការ ផ្នែកបំភ័ន្តអក្ខរៈ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១២ | នាយចំណង់ | **ដារ៉ា** | **សំណាង** | អត្តលេខ ០៩១៧៦២ ជំនួយការចលនូប្បត្ថម្ភ ផ្នែកសឹករងក្រុងកំពង់ឆ្នាំង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

| | | | | |
|---|---|---|---|---|
| ១៣ | ព្រិន្ទបាលឯក | ឌល្លា | សុវណ្ណា | អត្តលេខ ០៨៤៩៦១ មេបញ្ជាការរង ខ.គាំទ្រ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៤ | ព្រិន្ទបាលឯក | គង់ | សុវត្ថិ | អត្តលេខ ១០៨២១៨ បុគ្គលិកបំរើការ លេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៥ | ព្រិន្ទបាលឯក | សាន | ជឿន | អត្តលេខ ១១៣៩៨៣ មេបញ្ជាការរង ខ.បញ្ជូនសារ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៦ | ព្រិន្ទបាលឯក | អ៊ឹម | សុផាន់ណារ៉ា | អត្តលេខ ០៩១៧០១ បុគ្គលិកតែងតាំង ការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

**គ-មេដាយសិរីវឌ្ឍនភាពមាស**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ត្រី | សំហេត | ឫទ្ធីសំរិត្ថិ | អត្តលេខ ០៤០៨៩៧ ជំនួយការ ប្រតិបត្តិការ ការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២ | នាយចំណង់ | កេត | យ៉ា | អត្តលេខ ០៨៤៩៦៨ មេបញ្ជាការ ខ.គាំទ្រ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៣ | នាយចំណង់ | នង | សំអូន | អត្តលេខ ០៨៤៩៨៣ មេបញ្ជាការ ខ៣ គ២ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៤ | នាយចំណង់ | ហែម | ផុន | អត្តលេខ ២១៩៥៨៧ ជំនួយការបើកបរ ការិយាល័យបច្ចេកទេស តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៥ | នាយចំណង់ | ស៊ឹម | គឿន | អត្តលេខ ២១៩៥៩១ ជំនួយការពេទ្យបឋម ផ្នែកសឹករងក្រុងកំពង់លែង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៦ | នាយចំណង់ | អឿង | គីមហាន | អត្តលេខ ០៨៤៩៥៥ ជំនួយការចលនូប្បត្ថម្ភ ផ្នែកសឹករងបរិបូណ៌ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៧ | នាយចំណង់ | សុខ | ពៅ | អត្តលេខ ០៦៣៧២០ ជំនួយការលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៨ | ព្រិន្ទបាលឯក | ពៅ | ណារិទ្ធ | អត្តលេខ ០៩០៤៥៣ បុគ្គលិកគ្រប់គ្រង កងអនុសេនាធំលេខ៤ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ៩ | ព្រិន្ទបាលឯក | គីម | សុវណ្ណា | អត្តលេខ ០៥៦៨៧៣ មេបញ្ជាការរង ខ៣ កងអនុសេនាធំលេខ៤ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១០ | ព្រិន្ទបាលឯក | អ៊ុយ | វណ្ណះ | អត្តលេខ ០៩១៨៩២ បុគ្គលិកការិយាល័យអភិវឌ្ឍន៍ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១១ | ព្រិន្ទបាលឯក | មាស | យឿន | អត្តលេខ ១៧៨៨៥៥ បុគ្គលិកពេទ្យបឋម កងអនុសេនាធំលេខ៤ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១២ | ព្រិន្ទបាលឯក | ទឿន | សាគា | អត្តលេខ ០៩១៩១០ បុគ្គលិកជីវពល ផ្នែកសឹករងសាមគ្គីមានជ័យ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

| | | | | |
|---|---|---|---|---|
| ១៣ | ព្រិន្ទបាលឯក | ច្រាក់ | សុគ័ណ្ឌ | អត្តលេខ ០៨៤៩៧៧ មេបញ្ជាការរង ខ១ គ២ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៤ | ព្រិន្ទបាលឯក | ខុន | ហាក់ | អត្តលេខ ០៦៣៧២៥ បុគ្គលិកពេទ្យ គ២ វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៥ | ព្រិន្ទបាលឯក | ជា | សុគ័ន្ធ | អត្តលេខ ០៨៤៩៨០ បុគ្គលិកការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៦ | ព្រិន្ទបាលឯក | សុខ | ហួត | អត្តលេខ ០៩១៧៣៨ បុគ្គលិកហ្វឹកហ្វឺន ផ្នែកសឹករងក្រុងកំពង់ឆ្នាំង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៧ | ព្រិន្ទបាលឯក | អ៊ីុខ | អ៊ឹម | អត្តលេខ ១៣៩០២៨ បុគ្គលិក ការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៨ | ព្រិន្ទបាលឯក | គង់ | ចាន់ធឿន | អត្តលេខ ១១៣៣៤៤ បុគ្គលិក ការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ១៩ | ព្រិន្ទបាលឯក | យូ | គីមសេង | អត្តលេខ ១១៥៨២៨ បុគ្គលិក ការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២០ | ព្រិន្ទបាលឯក | ណាត | នាង | អត្តលេខ ១១៣៣៩១ បុគ្គលិក បំរើការ លេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |
| ២១ | ព្រិន្ទបាលឯក | ហែម | ឆាន | អត្តលេខ ១១៣២៩៩ មេបញ្ជាការរង កងអនុសេនាតូចស៊ើបការណ៍ការពារ តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង |

**មាត្រា ២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
  បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់**វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **គិន ឆន** អត្តលេខ ០៥៣៧៨ នាយនគរបាលជាតិជាន់ខ្ពស់នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧០១ - អនក្រ.បក**

# អនុក្រឹត្យ

**ស្តីពី**

**ការតែងតាំងមន្ត្រីនគរបាលជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១ :** តែងតាំងជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានចំនួន ០៣រូប មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស ដូចខាងក្រោម :

១- លោកវរសេនីយ៍ឯក **ស៊ុំ ដារិន** អត្តលេខ១២១៦២

២-លោកវរសេនីយ៍ត្រី **ហួរ ស៊ុយ** អត្តលេខ ១២១៥២

៣-លោកអនុសេនីយ៍ឯក **ណឹម ទុត្ថា** អត្តលេខ ១៧០០៥ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.**-បំពាក់ មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ ចំនួន ០៦គ្រឿង ជូនទីប្រឹក្សាបច្ចេកទេសក្រុមហ៊ុនសាងសង់ចិន  ចំនួន ០៦រូប  ដែលមានស្នាដៃល្អក្នុងការសហការ  និងសាងសង់ផ្លូវជាតិលេខ៤១  ពីថ្នល់ទទឹង(ខេត្តកំពង់ស្ពឺ) ដល់ជុំគិរី (ខេត្តកំពត) កន្លងមក សម្រេចបានជាស្ថាពរ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- | Mr. Lu Shan | General Manager of CRBC |
| ២- | Mr. Fang Zhen Hua | Project Manager of NR 41 |
| ៣- | Mr. Tian Zhong Jin | Deputy Project Manager |
| ៤- | Mr. Hou Yao | Vice General Manager |
| ៥- | Mr. Zhu Qing Feng | Senior Engineer |
| ៦- | Mr. Liu Dajun | Chief of Laboratory WACC |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មាធិការនៃគណៈកម្មាធិការ
## ចម្រុះកិច្ចការព្រំដែនគោក កម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៣១/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ១៧ សសរ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ថៃ
- បានឃើញតម្រូវការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១÷** បង្កើតអនុគណៈកម្មាធិការនៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនគោក ដែលមានសមាសភាពដូចតទៅ:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | ឯកឧត្តម **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៣- | ឯកឧត្តម **ប្រុក សារឿន** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |

| | | | | |
|---|---|---|---|---|
| ៤- | ឯកឧត្តម | **ជា ម៉ន** | មេបញ្ជាការយោធភូមិភាគ៤ | សមាជិក |
| ៥- | ឯកឧត្តម | **ប៊ុន សេង** | មេបញ្ជាការយោធភូមិភាគ៥ | សមាជិក |
| ៦- | ឯកឧត្តម | **អ៊ិត សុត្ថា** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- | ឯកឧត្តម | **ហេង រតនា** | អគ្គនាយក នៃមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា | សមាជិក |
| ៨- | ឯកឧត្តម | **ប្រាក់ សំអឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលទូទៅ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩- | ឯកឧត្តម | **ស៊ា ម៉ៅ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០- | ឯកឧត្តម | **ខេង សុមេធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១១- | ឯកឧត្តម | **ឡាយ សៀវលី** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១២- | ឯកឧត្តម | **ស៊ិន សុធានី** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១៣- | ឯកឧត្តម | **គង់ ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក និងជាលេខាធិការ |
| ១៤- | ឯកឧត្តម | **ហាក់ សុខហេង** | អគ្គលេខាធិការរងក្រុបប្រឹក្សាអ្នកច្បាប់ | សហជិក និងជាលេខាធិការ |
| ១៥- | លោក | **កែវ ទិសិដ្ឋ** | ប្រធាននាយដ្ឋានច្បាប់ និងកុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦- | លោក | **ប៊ុន សុខវិបុល** | អង្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ | សមាជិក |
| ១៧- | លោកស្រី | **ឡាយ ច័ន្ទរស្មី** | អនុប្រធាននាយកដ្ឋានអាស៊ី១ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨- | លោក | **ជា សម្បត្តិ** | ប្រធានការិយាល័យកិច្ចការព្រំដែននៃនាយដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ប្រការ២**÷អនុគណៈកម្មាធិការ នៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនគោកកម្ពុជា-ថៃ មានភារកិច្ចដូចតទៅ÷

(ក) ជាយន្តការឆ្លើយតប ក្នុងកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រថៃ ក្នុងដំណើរការចរចាកិច្ចការព្រំដែនដែលកំពុងប្រព្រឹត្តទៅ។

(ខ)- ជាយន្តការទំនាក់ទំនងសមភាគី ក្នុងកិច្ចការព្រំដែនជាមួយអនុគណៈកម្មាធិការថ្មី ដែលភាគីព្រះរាជាណាចក្រថៃទើបតែបានបង្កើតឡើង។

(គ)- ទទួលព័ត៌មានពីអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ថៃ ដើម្បីផ្តល់ការសម្របសម្រួលដល់ដំណើរការកិច្ចការចរចាកម្ពុជា-ថៃ ដែលកំពុងប្រព្រឹត្តទៅ។

**ប្រការ៣**÷សមាជិកនៃអនុគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន។

**ប្រការ៤**÷ អនុគណៈកម្មាធិការនេះមានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥**÷ អនុគណៈកម្មាធិការនេះ អាចស្នើសុំមូលនិធិសម្រាប់កិច្ចប្រជុំ រួមទាំងការចំណាយផ្សេងៗ និងឧបករណ៍ សម្ភារៈចាំបាច់នានា ក្នុងការបំពេញបេសកកម្ម។

**ប្រការ៦**÷ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤១ សសរ

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាព
នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៥ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញសេចក្តីសម្រេចលេខ០៥ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ ស្តីពីការតែងតាំងសមាសភាព នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

តែងតាំងឯកឧត្តម បណ្ឌិត **គុណា ញឹម** អគ្គនាយក អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាសមាជិកអាជ្ញាធរជាតិអាវុធគីមី ជំនួសឯកឧត្តម **ប៉ែន ស៊ីម៉ន** ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានអាជ្ញាធរជាតិអាវុធគីមី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៤២..ស.សរ

**សេចក្ដីសម្រេច**

**ស្ដីពី**

**ការតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិ**
**ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**
**នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តរតនគិរីដូចខាងក្រោម៖

១-ឯកឧត្តម **សុខ វិសាល** អនុរដ្ឋលេខាធិការក្រសួង មុខងារសាធារណៈ សមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តរតនគិរី ជាអនុប្រធានក្រុមការងារថ្នាក់ជាតិខេត្តរតនគិរី។

២-ឯកឧត្តម **ណុះ ស្លេះ** អនុរដ្ឋលេខាធិការក្រសួង អប់រំយុវជន និងកីឡា សមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តរតនគិរី ជាអនុប្រធានក្រុមការងារថ្នាក់ជាតិខេត្តរតនគិរី។

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តរតនគិរី និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០. ខែ មិថុនា ឆ្នាំ២០១៥

**ត.ប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤១៣ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន

## សម្រេច

**ប្រការ ១**: ត្រូវបានតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដូចខាងក្រោម ៖

| | |
|---|---|
| ១- ឯកឧត្តម ប្រាក់ សុខុន | ប្រធាន |
| ២- ឯកឧត្តម **ស ចាន់ធី** | អនុប្រធាន |
| ៣- ឯកឧត្តម **ឈឺវ យីស៊ាង** | អនុប្រធាន |

| | |
|---|---|
| ៤- ឯកឧត្តម ប្រាក់ ផល្លា | ទីប្រឹក្សា |
| ៥- ឯកឧត្តម រាល ម៉ារ៉ាវី | សមាជិក |
| ៦- ឯកឧត្តម ហេង សុវិទ្ធ | សមាជិក |
| ៧- ឯកឧត្តម លី សុខហេង | សមាជិក |
| ៨- ឯកឧត្តម ទាន សំណាង | សមាជិក |
| ៩- ឯកឧត្តម មៅ ទិត្យារុណ | សមាជិក |
| ១០- ឯកឧត្តម សាង បូរ៉ាណា | សមាជិក |
| ១១- ឯកឧត្តម ដាវ បុត្រមុនី | សមាជិក |
| ១២- ឯកឧត្តម សំលៀង សាលីន | សមាជិក |
| ១៣- ឯកឧត្តម ធុច ដាលីន | សមាជិក |
| ១៤- ឯកឧត្តម ម៉ែន ទន | សមាជិក |
| ១៥- កញ្ញា ព្រាប កែវច័ន្ទមុនី | សមាជិក |
| ១៦- កញ្ញា ប៉ែន ច័ន្ទដាវី | សមាជិក |
| ១៧- កញ្ញា សាយ សារ៉ាមី | សមាជិក |
| ១៨- កញ្ញា មាច សុភាវី | សមាជិក |
| ១៩- លោក ទូច សុរ៉ាណា | សមាជិក ។ |

**ប្រការ ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងស៊ើបអង្កេតពិសេស លើករណីបណ្តឹងលេខ ២៣១៨ ស្តីពីករណីឃាតកម្មលើមេដឹកនាំសហជីព ជា វិជ្ជា ហ៊ី វុទ្ធី និងរស់ សុវណ្ណារ៉េត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងស៊ើបអង្កេតពិសេសលើករណីបណ្តឹងលេខ២៣១៨ ស្តីពីករណីឃាតកម្មលើមេដឹកនាំសហជីព ជា វិជ្ជា ហ៊ី វុទ្ធី និងរស់ សុវណ្ណារ៉េត ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១រូប | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - តំណាងអាជ្ញាធរពាក់ព័ន្ធ | | សមាជិក។ |

**ប្រការ២ .-**

គណៈកម្មការនេះ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មាន និងភស្តុតាង
- ចុះស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយលើអង្គហេតុ និងអង្គច្បាប់
- រៀបចំរបាយការណ៍បំភ្លឺករណីបណ្តឹងនេះជូនអង្គការអន្តរជាតិខាងការងារ
- បំពេញការងារចាំបាច់ផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...០៥...សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦**

## I. សេចក្តីផ្តើម

១- មាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា៣ដំណាក់កាលគឺ (១) **ដំណាក់កាលទី១**: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនា ដល់ខែឧសភា (២) **ដំណាក់កាលទី២**: ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនាដល់ខែកញ្ញា និង(៣) **ដំណាក់កាលទី៣**: ការអនុម័តថវិកា ពីខែតុលាដល់ខែធ្នូ។ សម្រាប់ដំណាក់កាលទី១នេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ និងសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦។ ទន្ទឹមនេះដែរ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗបានរៀបចំ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ពន្យល់ និងធ្វើអំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូល និងតម្រូវការចំណាយសម្រាប់រយៈពេល៣ឆ្នាំរំកិល(២០១៦-២០១៨) សម្រាប់សម្រេចគោលបំណងគោលនយោបាយរបស់ខ្លួន ដែលជាការរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**"។ នៅក្នុងដំណាក់កាលទី២នេះ រាជរដ្ឋាភិបាល ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ សម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៦ របស់គ្រប់ក្រសួង ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ។ ក្នុងស្មារតីនេះ សារាចរនេះដាក់ចេញនូវក្របខណ្ឌ និងវិធានការប្រមូលចំណូល ការកំណត់អាទិភាពចំណាយតាមវិស័យ និងកំណត់គោលការណ៍សំខាន់ៗ សម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង ស្ថាប័នផងដែរ។ ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយ

ឡែកមួយទៀតចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដោយឈរលើមូលដ្ឋាននិងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការបែងចែកថវិកាទៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងភាពស័ក្តសិទ្ធនៃការប្រមូលចំណូល និងប្រសិទ្ធភាពនៃការបែងចែកនិងភាពស័ក្តសិទ្ធនៃការអនុវត្តចំណាយទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការ ក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និង រក្សាអតិរេកសាច់ប្រាក់។

២-ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ស្ថិតក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាកំពុងមានសុខសន្តិភាព ឯកភាពជាតិ និងស្ថិរភាពនយោបាយ ប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស,ព្រមទាំងមានការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់ផ្នែក និងគ្រប់វិស័យ ហើយកំពុងក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប។ ប្រការនេះបានបង្កលក្ខខណ្ឌអំណោយផល និងស្ថានភាពអនុគ្រោះ សម្រាប់ជាមូលដ្ឋានក្នុងការកសាងអនាគតកម្ពុជាមួយដ៏រុងរឿង និងត្រចះត្រចង់។ ទន្ទឹមនឹងនេះ ការពង្រឹកវប្បធម៌នៃការសន្ទនាគ្នា ដោយឈរលើមូលដ្ឋានគោរពឧត្តមប្រយោជន៍ជាតិ និងប្រជាជននាពេលថ្មីៗនេះ ក៏នឹងកាន់តែផ្តល់នូវឱកាស និងភាពងាយស្រួលដល់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅតាមឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាផង និង ដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូរជារចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជាផង ព្រមទាំងការប្រែប្រួលនិមាបនកម្មសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ទាំងក្នុងកម្រិតតំបន់ និងពិភពលោក។

៣- ទោះបីកម្ពុជាត្រូវជួបប្រទះនូវបញ្ហាប្រឈមគ្រប់បែបយ៉ាង ទាំងក្នុង និងក្រៅប្រទេសក៏ដោយ ក៏រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា, ចាប់តាំងតែពីដើមនីតិកាលរហូតមក, នៅតែអាចតស៊ូពុះពារ និងជំនះបាននូវរាល់ឧបសគ្គ និង ការលំបាកផងទាំងពួង ហើយធានាបាននូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាធានាបានល្អប្រសើរនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតទាបសមរម្យ, ធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងពង្រឹងឡើងថែមទៀតនូវសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញការអនុវត្តវិធានការនានា សំដៅពន្លឿនពិពិធកម្មសេដ្ឋកិច្ច រួមមានជាអាទិ៍ ការបង្កើនផលិតភាពនៃវិស័យកសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ និងការធ្វើឱ្យកាន់តែល្អប្រសើរនូវបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ដែលប្រការទាំងអស់នេះបានបង្កើតការងារជូនប្រជាជនកម្ពុជា, ពិសេសយុវជន, ជាច្រើនសែននាក់ក្នុងមួយឆ្នាំៗ។ ជាក់ស្តែង នៅក្នុងរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០១៤ ប្រទេសកម្ពុជាត្រូវបានចាត់បញ្ចូលក្នុងក្រុមប្រទេសឯកទត្តករកំណើនទាំងប្រាំបីនៅក្នុងពិភពលោក ( Olympians of Growth ) ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំ។

៤- ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលនៅឆ្នាំ២០១៥ និង២០១៦ ខាងមុខ ត្រូវបានវាយតម្លៃថាមានស្ថានភាពល្អ ទោះបីជាមានបញ្ហាវិវាទភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចនៅក្នុងតំបន់មួយចំនួនក្តី។ តាមការព្យាករ សេដ្ឋកិច្ចអាមេរិកនឹងនៅបន្តមានកំណើនល្អ ក្នុងខណៈដែលសេដ្ឋកិច្ច

តំបន់ចាយប្រាក់អឺរ៉ូត្រូវបានរំពឹងថាចាប់ផ្ដើមមានកំណើនជាវិជ្ជមានឡើងវិញ ទោះបីកំណើននេះមានកម្រិតទាបក៏ដោយ។ ចំណែកឯសេដ្ឋកិច្ចធំៗក្នុងតំបន់អាស៊ី ដូចជាជប៉ុនជាដើម នឹងបន្តមានកំណើនវិជ្ជមាន ហើយប្រទេសចិននឹងនៅតែអាចបន្តរក្សាកំណើនខ្ពស់បានដដែល ទោះបីជាយឺតជាងពេលមុនបន្តិចក៏ដោយ។ ចំណែកសេដ្ឋកិច្ចប្រទេសឥណ្ឌា និងអាស៊ាន៥ វិញ នឹងអាចរក្សាបានកំណើនក្នុងកម្រិតមធ្យមក្នុងរង្វង់ពី ៥% ទៅ ៦%។ ជានិន្នាការសកល តម្លៃប្រេងនឹងស្ថិតនៅក្នុងស្ថានភាពទាប, ថ្លៃកសិផលបន្តធ្លាក់ចុះ ហើយប្រាក់ដុល្លារអាមេរិករំពឹងថានឹងកើនឡើងតម្លៃ។ ការវាយតម្លៃខ្លះបានបង្ហាញថាសេដ្ឋកិច្ចពិភពលោកកំពុងស្ថិតក្នុងនិន្នាការនៃ "**ប្រក្រតីថ្មី**" បន្ទាប់ពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភព-លោក ឆ្នាំ២០០៨។ ជារួម ស្ថានភាពបែបនេះ នឹងផ្ដល់លក្ខណៈអំណោយផលមួយចំនួនដល់សេដ្ឋកិច្ចកម្ពុជា ប៉ុន្តែក៏បង្កើតឡើងនូវបញ្ហាប្រឈមថ្មីៗថែមទៀត។

៥- នៅក្នុងបរិបទតំបន់ ឆ្នាំ២០១៦ ជាឆ្នាំដែលតំបន់អាស៊ានកំពុងអនុវត្តក្របខណ្ឌសហគមន៍សេដ្ឋកិច្ចមួយ។ ពិតណាស់ថា នៅក្នុងដំណើរការសមាហរណកម្មនេះ កម្ពុជានឹងទទួលបាននូវផលប្រយោជន៍ច្រើន ពីលំហូរកាន់តែសេរីនូវទំនិញ មូលធន និងពលករជំនាញ ដែលជាឱកាសឱ្យកម្ពុជាប្រើប្រាស់បានកាន់តែច្រើននូវសក្ដានុពលសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលផ្សារភ្ជាប់ទៅនឹងអ្វីដែលគេហៅថា"**រោងចក្រពិភពលោក**"នៅតំបន់អាស៊ី។ ប៉ុន្តែកម្ពុជាអាចនឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមានមួយចំនួននៅក្នុងរយៈពេលខ្លីផងដែរ ពិសេសការថយចុះនៃចំណូលពន្ធពីពាណិជ្ជកម្មអន្តរជាតិដែលអាចប៉ះពាល់ជាយថាហេតុដល់ចីរភាពថវិកា។ ក្នុងន័យនេះ កម្ពុជាចាំបាច់ត្រូវបន្តរៀបចំខ្លួនឱ្យបានល្អពិសេសការបន្តនូវការកែទម្រង់សំខាន់ៗ ស្របតាមការតម្រូវដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងតទៅអនាគត ព្រមទាំងត្រូវបន្តធ្វើការកែទម្រង់លើគ្រប់វិស័យឱ្យបានខ្លាំងក្លា និងស៊ីជម្រៅបន្ថែមទៀតដើម្បីពង្រឹងភាពប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគ និងបង្កើនតម្លៃបន្ថែមឱ្យបានខ្ពស់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ឱ្យមានចីរភាព។

៦- ដោយផ្អែកលើចំណុចខ្លាំង, កត្តាអំណោយផល, បញ្ហាប្រឈម និងហានិភ័យ ដូចខាងលើ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ត្រូវបានកំណត់លើមូលដ្ឋានសុទិដ្ឋិនិយម ជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ដែលរួមមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

## II. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៦

### ក. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៦

៧- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា នៅតែមានលក្ខណៈរឹងមាំនៅក្នុងឆ្នាំ២០១៤ និងក្នុងរយៈពេលមធ្យម ដោយសារកំណើនខ្ពស់នៃវិស័យសំណង់ ភាពល្អប្រសើរនៃវិស័យទេសចរណ៍ និងការនាំចេញសំលៀកបំពាក់មានភាពកាន់តែប្រសើរ ជាមួយនឹងការធ្លាក់ចុះនៃថ្លៃប្រេងទីផ្សារអន្តរជាតិ។ នៅក្នុងឆ្នាំ ២០១៤ កន្លងទៅ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនក្នុងអត្រា ៧% តាមការរំពឹងទុក ជាមួយនឹង

អតិផរណាមធ្យមប្រចាំឆ្នាំ ក្នុងអត្រាប្រមាណ ៣,៩% និងអត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៣៩រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៤ សម្រេចបានល្អ ដោយសារ (១)-វិស័យឧស្សាហកម្មមានកំណើន ១០,៤% ដែលក្នុងនោះ វិស័យសំណង់បាននាំមុខជាលើកទីមួយដោយមានកំណើនរហូតដល់២១,៤% និងវិស័យកាត់ដេរសម្រេចបានកំណើន ៦,៩% (២)-វិស័យសេវាមានកំណើន ៩,១% ដែលក្នុងនោះ វិស័យទេសចរណ៍មានកំណើន ៧,៣% និងវិស័យអចលនទ្រព្យមានកំណើន ១៣,៨% និង (៣)-វិស័យកសិកម្មបានធ្លាក់ចុះ ១,៤% ដែលក្នុងនោះ វិស័យជលផលធ្លាក់ចុះ ៨,៨% និងដំណាំមានកំណើន ១,៥%។ ការបន្តមានកំណើនខ្ពស់បែបនេះ បានធ្វើឱ្យចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ៗ កើនឡើងដល់១ ១២៣ដុល្លារអាមេរិក ជាកម្រិតចំណូលដែលកម្ពុជាកំពុងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

៨- នៅក្នុងឆ្នាំ២០១៥ និង ឆ្នាំ២០១៦ តាមការព្យាករ កម្ពុជានឹងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧%, ហើយផ.ស.ស.តាមថ្លៃចរន្តឆ្នាំ២០១៥ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន៧៤ ៤៦០ ៩៣៨ លានរៀល និង ផ.ស.ស.តាមថ្លៃចរន្តឆ្នាំ២០១៦ ត្រូវបានគ្រោងចំនួន៨១ ៩៣៤ ៣៣៣ លានរៀល ។ កំណើននេះ បានមកពី៖

- វិស័យកសិកម្ម អាចសម្រេចបានកំណើនប្រមាណ ៤,៥% នៅឆ្នាំ២០១៥ និងប្រមាណ ៤,៣% នៅឆ្នាំ២០១៦ ក្នុងនោះដោយសារការកើនឡើងនូវដំណាំស្រូវ និងដំណាំឧស្សាហកម្ម ពិសេសកៅស៊ូដែលនឹងបន្តកើនឡើងក្នុងកម្រិតខ្ពស់ ព្រោះផ្ទៃដីត្រូវដល់ពេលប្រមូលផលមានចំនួនកាន់តែច្រើន។ ប៉ុន្តែ វិស័យកសិកម្ម នឹងត្រូវប្រឈមជាមួយនឹងបញ្ហាផលិតភាពទាប ពិសេសដំណាំស្រូវ។ ក្នុងន័យនេះ ដើម្បីសម្រេចបាននូវកំណើនខាងលើ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាផលិតភាពទាបនេះ តាមរយៈការបន្តវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា, ការផ្សព្វផ្សាយកសិកម្ម និង ការសិក្សាស្រាវជ្រាវ, ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទាន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់ផងដែរលើការជំរុញមច្ឆវប្បកម្ម និងការចិញ្ចឹមសត្វបន្ថែមដោយផ្សារភ្ជាប់ជាមួយនឹងការគិតគូរទៅដល់តុល្យភាពបរិស្ថាន។

- វិស័យឧស្សាហកម្មអាចនឹងសម្រេចបានកំណើនប្រមាណ ៩,៦% នៅឆ្នាំ២០១៥ និងរក្សា ៩,៦% នៅឆ្នាំ២០១៦ ដោយសារការបន្តកើនឡើងនៃវិស័យកាត់ដេរ ការបន្តការរីកចម្រើននៃវិស័យថាមពល និងសំណង់ ព្រមទាំងការរីកចម្រើននៃវិស័យឧស្សាហកម្មធុនស្រាល ពិសេសសក្តានុពលក្នុងការនាំចេញផលិតផលឧស្សាហកម្មមួយចំនួន ដូចជាគ្រឿងបង្គុំអេឡិចត្រូនិចជាដើម។ វិស័យសំណង់នឹងមានកំណើនថមថយបន្តិចមកវិញ ដោយសារវដ្តនៃកំណើនវិស័យនេះជាធម្មតាតែងមានរយៈពេលមួយខ្លី ហើយវិស័យកាត់ដេរនឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល។ ក៏ប៉ុន្តែចំណែកទីផ្សារនៃផលិតផលសំលៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាក្នុងពិភពលោក មាននិន្នាការធ្លាក់ចុះក្នុងខណៈដែលកំណើននៃការធ្វើពាណិជ្ជកម្មផលិតផលនេះនៅលើទីផ្សារពិភពលោកមានការកើនឡើង បើទោះបីរាជរដ្ឋាភិបាលបានខិតខំជួយទ្រទ្រង់វិស័យនេះច្រើនមកហើយក្តី។ មូលហេតុនៃការធ្លាក់ចុះនេះ បណ្តាលមកពីការកើនឡើងនូវសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសជិតខាងយើងក្នុងតំបន់ ក្នុងខណៈដែលវិស័យកាត់ដេររបស់កម្ពុជា នៅមានផលិតភាពទាប, បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ និងនិន្នាការនៃការ

កើនឡើងនូវប្រាក់ឈ្នួល ព្រមទាំងបញ្ហាផ្នែកសម្របសម្រួលស្ថាប័ន និងនីតិវិធីពាក់ព័ន្ធ។ ដើម្បីដោះ-ស្រាយបញ្ហានេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ដល់ការបង្កើនផលិតភាពការងារ, ការបន្តធ្វើសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ ពិសេសការបង្កើនតម្លៃបន្ថែមរបស់វិស័យកាត់ដេរ និងការកែលម្អនីតិវិធីរដ្ឋបាល ព្រមទាំងការសម្រួលពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ ដើម្បីជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងបង្កើនការវិនិយោគសាធារណៈលើវិស័យអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេស ឱ្យសមស្របតាមតម្រូវការទីផ្សារ, ការផ្គត់ផ្គង់ថាមពលអគ្គិសនី, និងការ-អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទឱ្យក្លាយជាប្រព័ន្ធឡូជីស្ទីកមួយដ៏រស់រវើក និងមានភាពប្រកួតប្រជែងនៅក្នុងគោលដៅលើកកម្ពស់វិនិយោគ, ពាណិជ្ជកម្ម, ទេសចរណ៍ និង អភិវឌ្ឍន៍ជនបទ ព្រមទាំងការធ្វើឱ្យប្រសើរឡើងថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម។

- កំណើនក្នុងវិស័យសេវាអាចនឹងសម្រេចបាន ៦,៦% នៅឆ្នាំ ២០១៥ និង ៦,៥% នៅឆ្នាំ ២០១៦ ដោយសារការកើនឡើងនៃវិស័យដឹកជញ្ជូននិងទូរគមនាគមន៍, វិស័យទេសចរណ៍, វិស័យហិរញ្ញវត្ថុ និងអចលនទ្រព្យ ជាពិសេសសេវាគាំទ្រផ្នែកឧស្សាហកម្ម។ វិស័យទេសចរណ៍នឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល ប៉ុន្តែចាំបាច់ត្រូវបន្តធ្វើពិពិធកម្មឱ្យអស់សក្តានុពល ដើម្បីបង្កើនតម្លៃបន្ថែមនៃវិស័យនេះ ក្នុងសេដ្ឋកិច្ចជាតិ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើហានិភ័យមួយចំនួន ដែលអាចកើតឡើងពីផ្នែកអចលនទ្រព្យ និងមីក្រូហិរញ្ញវត្ថុ, ទន្ទឹមនឹងការជំរុញរកិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែខ្លាំងក្លា ទាំងវិស័យធនាគារ ទាំងវិស័យមិនមែនធនាគារ។

- អតិផរណាស្ថិតនៅក្នុងកម្រិតគ្រប់គ្រងបាន ទោះបីមានការប្រែប្រួលថ្លៃសម្ភារប្រើប្រាស់ និងម្ហូបអាហារ មួយចំនួនក៏ដោយ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០១៥ និងឆ្នាំ ២០១៦ រំពឹងថានឹងមានកម្រិតក្នុងរង្វង់ ៣,៥% ដោយសារតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិនៅតែមានកម្រិតទាប និង ថ្លៃកសិផលមានការធ្លាក់ចុះ។ អត្រាប្តូរប្រាក់ រំពឹងថាមានតម្លៃជាមធ្យម៤ ០៥០ រៀលក្នុង ១ដុល្លារអាមេរិក នៅឆ្នាំ២០១៥ និងឆ្នាំ២០១៦។ ប្រាក់រៀលរំពឹងថាបន្តមានស្ថិរភាព និងមានបរិមាណកើនឡើង ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងការជឿទុកចិត្តពីសាធារណជន ពិសេសការបន្តអនុវត្តគោល-នយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុសមស្រប ព្រមទាំងការអនុវត្តគោលនយោបាយជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

- នៅឆ្នាំ ២០១៤ ឱនភាពគណនីចរន្តបានថយចុះមកត្រឹម ១១,២% នៃផ.ស.ស (ធ្លាក់ពី ១២,៥% នៃផ.ស.ស ក្នុងឆ្នាំ២០១៣) ដោយសារការកើនឡើងការនាំចេញលឿនជាងការនាំចូល។ តាមការព្យាករ ឱនភាព គណនីចរន្តរំពឹងថានឹងបន្តធ្លាក់ចុះដល់ ១០,៣% នៃផ.ស.ស នៅឆ្នាំ ២០១៥ និង ៩,៧% នៃផ.ស.ស នៅឆ្នាំ២០១៦។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួន ចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ ២០១៥ ទុនបម្រុងនឹងមានទំហំ

៥ ១៤៤ លានដុល្លារអាមេរិក និងអាចកើនឡើងលើសពី ៥ ៧៣៩ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៦ ដែលធានាបានប្រមាណជាង ៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

៩- ជារួមក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើង ដើម្បីរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពតម្លៃ ការបង្កើតការងារ និងចីរភាពថវិកា និងបំណុល ព្រមទាំងស្ថិរភាពជញ្ជីងទូទាត់។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅកំណើន ផ.ស.ស ឱ្យសម្រេចបានក្នុងរង្វង់ ៧% សម្រាប់ឆ្នាំ ២០១៥ និងឆ្នាំ ២០១៦។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតនៅក្រោម ៥% ក្នុងមួយឆ្នាំ ពោលគឺនៅក្នុងរង្វង់ ៣,៥% នៅឆ្នាំ ២០១៥ និង នៅឆ្នាំ ២០១៦ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុង ១ដុល្លារសហរដ្ឋអាមេរិក ដោយខិតខំជំរុញបដិដុល្លារូបីយកម្មសេដ្ឋកិច្ចនៅចំពោះមុខ និងរយៈពេលវែង។

## ខ- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០១៦

១០- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៦ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៦ និង **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** និង **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨"** ដោយមានគោលបំណងសំខាន់ៗ ដូចតទៅ៖

- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ននិងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព
- ធានាការការពារអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសុខសន្តិភាព សន្តិសុខ ស្ថិរភាព នយោបាយ និងសណ្តាប់ធ្នាប់សាធារណៈសង្គម
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- ជំរុញអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀល នៅឆ្នាំ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសារណៈ ២០១៥-២០១៨ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗរួមមានៈ ការកែទម្រង់ប្រព័ន្ធកងកម្លាំង

ប្រដាប់អាវុធ, ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ, ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ

- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈនិងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល
- បន្តជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ
- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាសម្រាប់គាំទ្រដល់កំណើន និងការអភិវឌ្ឍ
- ធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាព
- បន្តការជំរុញការអភិវឌ្ឍវិស័យកសិកម្ម ពិសេសបន្តធានាការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងផលិតកម្មម្ហូបអាហារ
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព
- បន្តពង្រឹងស្ថាប័នសាធារណៈ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព ពង្រីកការទទួលបានភាពពេញចិត្តនិងប្រសិទ្ធភាពនៃសេវាសាធារណៈ។

១១- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ចបានរៀបរាប់រួចមកហើយ និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០១៦ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ទាំងផ្នែកចំណូល និង ផ្នែកចំណាយសម្រាប់ឆ្នាំ២០១៦ ដូចខាងក្រោម៖

## ក្របខណ្ឌចំណូលថវិកាឆ្នាំ ២០១៦

១២- គម្រោងចំណូលថវិកាឆ្នាំ២០១៦ ត្រូវបានកំណត់ដូចតទៅ ៖

-ចំណូលសរុបក្នុងប្រទេសសម្រាប់ឆ្នាំ២០១៦ គ្រោងសម្រេចឱ្យបាន១៧,៥១% នៃផ.ស.ស. គឺមានកំណើន១,៦៥ពិន្ទុភាគរយនៃផ.ស.ស. ឬកើន ២១,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ (ច្បាប់ឆ្នាំ២០១៥) ក្នុងនោះ

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ១៧,៣៥% នៃផ.ស.ស. គឺកើនឡើង ១,៦៧ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន ២១,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ **ចំណូល**

**ពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**ត្រូវគ្រោងសម្រេចឱ្យបាន៨,៤២%នៃផ.ស.ស. គឺមានកំណើន១,៣៤ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន៣០,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៥, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៥,៧០%នៃផ.ស.ស. គឺមានកំណើន ០,២៩ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន១៦,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥, **ចំណូលសារពើពន្ធផ្សេងទៀត**ត្រូវសម្រេចឱ្យបាន០,៣៦% នៃផ.ស.ស. គឺមានកំណើន ០,០២ពិន្ទុភាគរយនៃផ.ស.ស. ឬកើន ១៦,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥, និង**ចំណូលមិនមែនសារពើពន្ធ**ត្រូវគ្រោងសម្រេចឱ្យបាន១,៩៩% នៃផ.ស.ស. គឺ ថយចុះ ០,០២ ពិន្ទុភាគរយនៃផ.ស.ស. តែមានកំណើន ៨,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៥។

- **ចំណូលមូលធន**ក្នុងស្រុកត្រូវសម្រេចឱ្យបាន០,១៦% នៃផ.ស.ស. គឺថយចុះ ០,០២ពិន្ទុភាគរយ នៃផ.ស.ស. ឬថយ ២,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥។
- ដោយឡែក **ហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន៤,៩២%នៃផ.ស.ស. គឺថយចុះ០,៤៣ ពិន្ទុភាគរយនៃផ.ស.ស. តែមានកំណើន ១,២% ធៀបនឹងច្បាប់ឆ្នាំ២០១៥។

១៣- ជារួមដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬតម្លើងពន្ធបន្ថែមដល់ប្រជាជន និងធុរជននោះទេ។ រាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយនិងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធនិងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និង ផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ជាពិសេស តាមរយៈការជំរុញអនុវត្តប្រកបដោយភាពស័ក្តិសិទ្ធនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ដែលក្នុងនោះ ក្របខណ្ឌនៃវិធានការសំខាន់ៗ មានដូចតទៅ៖

១៤- **វិធានការផ្នែកចំណូលគយ និងរដ្ឋាករ មានដូចខាងក្រោម៖**

- បន្តពង្រឹងវិធានបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគយគ្រប់រូបភាព
- បន្តពង្រឹងការប្រកាសគយ តាមរយៈការពង្រឹងការគ្រប់គ្រងឯកសារនាំចេញ-នាំចូល និងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ពិសេសចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួន
- ពង្រឹងការកំណត់ និង ធ្វើចំណាត់ថ្នាក់ហានិភ័យ តាមរយៈការកែលម្អប្រព័ន្ធគ្រប់គ្រងហានិភ័យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ
- ពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីបង្កើនអនុលោមភាពនៃការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយឱ្យបានត្រឹមត្រូវ

- សិក្សា និងវាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយ លើទំនិញនាំចេញ-នាំចូល ក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការ កំណត់ពន្ធគយ និងដើម្បីបញ្ចៀសនូវការបាត់បង់ចំណូល
- ជំរុញការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដាឱ្យអស់សក្តានុពល ដើម្បីធានាឱ្យប្រព័ន្ធអាស៊ីគូដាអាចអនុវត្តបានទាំងស្រុងនូវមុខងារទាំងអស់ និងដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ចរជាតិតែមួយឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន
- បន្តពង្រឹងយន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន
- វាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយ ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប
- រៀបចំផែនការអភិវឌ្ឍស្ថាប័ន កែលម្អការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ។

**១៥- វិធានការផ្នែកចំណូលពន្ធដារ មានដូចខាងក្រោម៖**

- បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំង-អស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនិងប្រមូលចំណូល
- បន្តពង្រឹង និងកែលម្អការផ្តល់សេវាដល់អ្នកជាប់ពន្ធ
- បន្តកែលម្អការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតទៅលើ៖ (១). ការរៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ, (២).អនុវត្តវិធានការលុបចោលការចុះបញ្ជីឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ ខែជាប់គ្នា, និង (៣). កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាសឱ្យបានខ្ពស់ជាអតិបរមា បន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងប្រសិទ្ធភាព និង ធ្វើឱ្យប្រសើរឡើងនូវការធ្វើសវនកម្មពន្ធដារ ទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដោយផ្តោតការយកចិត្តទុកដាក់លើ៖ (១).កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើ-សវនកម្ម និងរៀបចំសារាចរណែនាំដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួម ដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម, (២) រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យមុនពេលចុះសវនកម្ម និងសម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ, (៣).

ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់និងបន្ថយបន្ទុកសវនកម្ម និង (៤). រៀបចំសាលាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមានៈ ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម

- បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជា ការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ
- ជំរុញការបង្កើនចំណូលពីអាករលើតម្លៃបន្ថែម តាមរយៈ៖ (១). រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត, (២).បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យដែលមិនមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ពង្រឹងការគ្រប់គ្រងរបបម៉ៅការ និងជំរុញការអនុវត្តរបបស្វ័យប្រកាស តាមរយៈ៖ (១). រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំរួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តង ឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែងដែលមានចំណូលខ្ពស់, (២). រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំព្រួញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។
- ពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគ
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរមូលដ្ឋាន ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- បន្តពង្រឹងកម្មវិធីផ្សព្វផ្សាយ និងការអប់រំពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីពន្ធដារ។

**១៦- វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម៖**

- ពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយធ្វើ-សវនកម្ម ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូល

ចំណូលប្រភេទនេះ ពិសេសរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- ពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេស រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បន្តតាមដានការប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានវិធានការលើកទឹកចិត្តសមស្របសម្រាប់ស្ថាប័នទាំងឡាយណា ដែលប្រមូលចំណូលបានល្អ និងមានវិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀត
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ រួចបង្កើតយន្តការតឹងទារបំណុលទាំងនោះដោយចាត់វិធានការព្រមាន ដកហូតអាជ្ញាបណ្ណ លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀត តាមការ-អនុញ្ញាតរបស់ច្បាប់ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល
- ពង្រឹងការគ្រប់គ្រងកាស៊ីណូ និងចំណូលពីកាស៊ីណូ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ
- ពង្រឹងការគ្រប់គ្រងធនធានប្រេងកាត និងរ៉ែ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ, ទន្ទឹមនឹង ការសិក្សា និងធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ, ការបន្តរៀបចំទិន្នន័យ និងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យានិងអាជ្ញាបណ្ណដែលបានផ្តល់រួច
- រៀបចំ និងដាក់ឱ្យអនុវត្តឱ្យមានប្រសិទ្ធភាពនូវការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគ-ហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និង តំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងការប្រមូលចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជាការលក់សំបុត្រទស្សនាប្រាសាទ រមណីយដ្ឋាន និងទីតាំងប្រវត្តិសាស្ត្រផ្សេងៗ
- បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត ,ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ, ប្រចាំត្រីមាស, ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀង-ទាត់ និងច្បាស់លាស់

- ពង្រឹងការបង់ចំណូលថវិកាពីថ្លៃសម្បទានដីសេដ្ឋកិច្ច និងផល-អនុផលព្រៃឈើពីព្រៃឈើពីសម្បទានិក តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួន ពាក់ព័ន្ធនឹងការលក់និងការផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច, នីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច, ការបង្កើនយន្តការនិងនីតិវិធីក្នុងការគ្រប់គ្រងនិងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើដីសម្បទានសេដ្ឋកិច្ច, វារីអគ្គិសនី, ទំនប់ អាង ស្រោចស្រព និងពីប្រភពផ្សេងៗទៀត
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងប្រសិទ្ធភាពការប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណក្នុងវិស័យទេសចរណ៍ តាមរយៈការបង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការធ្វើចំណាត់ថ្នាក់សណ្ឋាគារ និងការបង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ
- បន្តពង្រឹងការគ្រប់គ្រង និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសសាធារណៈទាំងអស់តាមរយៈត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ, ធ្វើការផ្ទៀងផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌ និងការធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុ, ព្រមទាំងពង្រឹងការអនុវត្តនូវកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋ
- ពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការសិក្សា និងរៀបចំឡើងវិញនូវក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងការកែលម្អលក្ខន្តិកៈគតិយុត្តឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និង ដើម្បីផ្តល់លទ្ធភាពដល់អង្គភាពរដ្ឋទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថាន ក៏ដូចជាដើម្បីជំរុញការអភិវឌ្ឍស្ថាប័នរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានស្រាប់,
- លើកកម្ពស់ការគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍ និងជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍,
- ធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សា អំពីភាពប្រកួតប្រជែងរបស់កម្ពុជា ពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗនៅក្នុងតម្លៃនៃការធ្វើធុរកិច្ច, អាជីវកម្ម និងពាណិជ្ជកម្មជារួមដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវានិងរង្វាន់លើកទឹកចិត្តផ្សារភ្ជាប់ជាមួយនឹងការកែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា,
- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ
- ពិនិត្យឡើងវិញ និងធ្វើកែប្រែជាយថាហេតុលើកិច្ចព្រមព្រៀងឬកិច្ចសន្យាណាមួយ ដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល

- ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ និងការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។

## ***ក្របខណ្ឌចំណាយថវិកាឆ្នាំ ២០១៦***

១៧- គម្រោងចំណាយថវិកាឆ្នាំ២០១៦ ត្រូវបានកំណត់ និងវិភាជ ដូចតទៅ ៖

- ចំណាយសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវបានគ្រោងត្រឹម២១,២៨%នៃផ.ស.ស. គឺកើនឡើង ០,២០ពិន្ទុភាគរយនៃផ.ស.ស. ឬកើន១១,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៥(ច្បាប់ឆ្នាំ២០១៥)។ ក្នុងនោះ**ចំណាយចរន្ត**នឹងកម្រិតត្រឹម១៣,២៨% នៃផ.ស.ស. (កើនឡើង០,១១ពិន្ទុភាគរយ នៃផ.ស.ស. ស្មើនឹង១០,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៥) ដោយផ្តោតអាទិភាពលើការបង្កើន**ចំណាយបៀវត្ស**សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យបាន ៤៨,៤៨% នៃចំណាយចរន្តសរុប ឬ ស្មើប្រមាណ ៦,៤៤% នៃផ.ស.ស.។ **ចំណាយមូលធន**នឹងត្រូវរក្សាឱ្យនៅត្រឹម៨,០%នៃផ.ស.ស. គឺកើនឡើង ០,០៩ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន១១,២% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុក** ត្រូវកំណត់ក្នុងកម្រិត ២,៦៥%នៃ ផ.ស.ស. គឺកើនឡើង ០,២៧ពិន្ទុភាគរយនៃផ.ស.ស. ឬកើន២២,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៥ និង**ចំណាយសម្រាប់វិលស់បំណុល**ត្រូវកំណត់ត្រឹម០,៦២% នៃផ.ស.ស. គឺកើន ០,៣០ពិន្ទុភាគរយនៃផ.ស.ស. ឬកើន១៦,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ **ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស**ត្រូវបានគ្រោងក្នុងកម្រិត៤,៧២%នៃផ.ស.ស. គឺថយចុះ០,២៣ ពិន្ទុភាគរយនៃផ.ស.ស. តែមានកំណើន ៥% ធៀបនឹងច្បាប់ឆ្នាំ២០១៥។
- **ចំណាយចរន្តថវិកាថ្នាក់ជាតិ**ត្រូវបានវិភាជទៅតាមវិស័យនីមួយៗ ដូចតទៅៈ **វិស័យសង្គមកិច្ច**ស្មើនឹង ៤,៨៤%នៃផ.ស.ស. គឺមានកំណើន ០,០៣ពិន្ទុភាគរយ នៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥, **វិស័យសេដ្ឋកិច្ច**ស្មើនឹង ១,៣៥%នៃផ.ស.ស. គឺមានកំណើន០,០១ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥, **វិស័យរដ្ឋបាលទូទៅ**ស្មើនឹង ១,៦៨%នៃផ.ស.ស. គឺទាបជាង ០,០៩ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥, **វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** ស្មើនឹង ៣,១០%នៃផ.ស.ស. គឺទាបជាង ០,០១ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥។ ជារួម កំណើនចំណាយនៅឆ្នាំ២០១៦ គឺត្រូវបានផ្តល់អាទិភាពលើការតម្លើងបៀវត្សមន្ត្រីរាជការ។
- ថវិការាជធានី ខេត្ត, ក្រុង ស្រុក ខណ្ឌ និង ឃុំ-សង្កាត់ ត្រូវកំណត់ត្រឹម១,៣៧%នៃផ.ស.ស មានកំណើន០,០៦ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥ ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧៥%នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់

ជាតិដល់រាជធានី ខេត្ត ស្មើនឹង ០,១៣%នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ក្រុង ស្រុក ខណ្ឌ ស្មើនឹង០,១២%នៃផ.ស.ស. ឬស្មើនឹង០,៩% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ ឆ្នាំ២០១៥, និង ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០១៥ ស្មើនឹង ០,១២%នៃផ.ស.ស. ឬស្មើនឹង ២,៨០%នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៥។

១៨- ក្នុងក្របខណ្ឌនៃគោលដៅចំណាយខាងលើនេះ រាជរដ្ឋាភិបាល នឹងជំរុញការអនុវត្ត យុទ្ធសាស្ត្រ និង ក្របខណ្ឌនៃវិធានការដើម្បី ***បង្កើនប្រសិទ្ធភាពចំណាយ*** ដូចខាងក្រោម៖

- បង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើន ប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ ពិសេសការ ពង្រឹងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ពីចំនួន១០ ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ២០១៥ ឱ្យឡើងដល់ ២៥ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៦
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃ លុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និង ភាពទាន់ពេលក្នុងចំណាយថវិកា ទាំងចំណាយចរន្ត (ចំណាយបន្ទុកបុគ្គលិក និងចំណាយ មិនមែនបន្ទុកបុគ្គលិក) និង ចំណាយមូលធន
- ពង្រឹងការគ្រប់គ្រង និងការជ្រើសរើសមន្ត្រីរាជការឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ រួមទាំង បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ក្នុងគោលបំណងឈានទៅសម្រេចគោលដៅនៃ ការតម្លើងបៀវត្សជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ឱ្យបានច្រើនជាង១ លានរៀល នៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង បង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដើម្បីសន្សំថវិកា យកទៅអនុវត្តសកម្មភាពអាទិភាព ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងបង្កើនផលិតភាព និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយក្នុងគោលបំណងរក្សាឲនភាពថវិកាឱ្យនៅត្រឹម កម្រិតសមរម្យមួយដែលមិនប៉ះពាល់ចិរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបង្កើន **"លំហថវិកា"** សម្រាប់ដោះស្រាយតម្រូវការបន្ទាន់ ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវ ការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត ព្រមទាំងការកាត់បន្ថយការ ពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- អនុវត្តឱ្យមានប្រសិទ្ធភាពនូវក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល ព្រមទាំង ពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ

- បង្កើនការសន្សំសំចៃថវិកា តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពចំណាយថវិកាលើមុខចំណាយទំនិញ និងសេវា មួយចំនួនដូចជា ប្រេងឥន្ធនៈ អគ្គិសនី សេវាទូរគមនាគមន៍ និងអ៊ិនធើណែត ការកាត់បន្ថយនូវបេសកកម្ម ទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណិតហើយមានតម្លៃខ្ពស់
- បន្តផ្តល់អាទិភាពចំណាយលើវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ
- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ និង ប្រព័ន្ធធារាសាស្ត្រស្រោចស្រព
- បន្តវិនិយោគលើការពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន និង មន្ទីរពេទ្យ ។ល។
- បង្កើនវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និង ជំរុញការកែច្នៃ និងនាំចេញផលិតកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីគាំទ្រដល់ការជំរុញផលិតកម្មម្ហូបអាហារ
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុក-ចិត្ត បាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ
- អនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ។

## ***ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ ២០១៦***

១៩- រាជរដ្ឋាភិបាល មានការចាំបាច់ក្នុងការធ្វើវិចារណកម្មចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកាឱ្យមកត្រឹមកម្រិតមួយសមរម្យ ស្របតាមគោលការណ៍អន្តរជាតិ និងតំបន់ តាមរយៈការរឹតបន្តឹងនិងសន្សំសំចៃចំណាយ ដើម្បីបង្កើន **"លំហថវិកា"** សម្រាប់ដោះស្រាយសេចក្តីត្រូវការបន្ទាន់ក្នុងការងារអភិវឌ្ឍន៍ ក៏ដូចជាសម្រាប់ត្រៀមជាយថាហេតុចាំបាច់ផ្សេងទៀត ពិសេសត្រៀមសម្រាប់ដោះស្រាយទប់ទល់នឹងវិបត្តិ ដោះស្រាយបញ្ហាគ្រោះធម្មជាតិ ដោះស្រាយតម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យនិងបូរណភាពទឹកដី ក៏ដូចជាសម្រាប់ឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអនុវត្តគោលនយោបាយថ្មី ដែលអាចត្រូវបានដាក់ចេញនៅក្នុងឆ្នាំអនុវត្ត។ ក្នុងក្របខ័ណ្ឌចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០១៦ គ្រោងសម្រេចឱ្យបានប្រមាណ ៤,០៧% នៃផ.ស.ស. ចំណែកឯឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយឱ្យនៅត្រឹម៣,៧៧% នៃផ.ស.ស.។ ការថយចុះនៃឱនភាពថវិកានឹងជួយដល់ការគ្រប់គ្រងបំណុលប្រកបដោយចីរភាពក្នុងគោលដៅជំរុញការអភិវឌ្ឍនៅក្នុងល្បឿនខ្ពស់។ ទំហំ

តុល្យភាពខាងលើ គឺអាចធានាបាននូវថវិកាភាពថវិកាដែលជាកត្តាគន្លឹះសម្រាប់ធានាបាននូវស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច សម្រាប់ផ្តល់ភាពអនុគ្រោះដល់កំណើនសេដ្ឋកិច្ច ជាពិសេស បង្កើននូវប្រាក់បញ្ញើរបស់រាជ-រដ្ឋាភិបាលឡើងវិញ ដើម្បីមានមូលដ្ឋានកាន់តែរឹងមាំសម្រាប់ទប់ទល់នឹងវិបត្តិខាងក្រៅ និងកាត់បន្ថយហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ។

## III- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៦

### ក- ការគ្រោងចំណូលថវិកាឆ្នាំ២០១៦

២០- ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង លក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបានដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និង គោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

### ខ-ការគ្រោងចំណាយថវិកាឆ្នាំ២០១៦

២១- ចំពោះ**ក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធី** ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ការរៀបចំថវិកាត្រូវយកចិត្តទុកដាក់អំពីប្រសិទ្ធភាពនៃការបែងចែកថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និង ជាពិសេស លទ្ធផលឬធាតុចេញ (Output)ដែលនឹងសម្រេចបាន ដើម្បីសម្រេចគោលបំណងគោលនយោបាយដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ ប្រការនេះ ជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ធ្វើជាអំណះអំណាង និងគាំទ្រដល់ការរៀបចំ និងការចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការនីតិវិធីអនុវត្តចំណាយ។ ដោយឡែក ចំពោះ **ក្រសួង ស្ថាប័នអនុវត្តថវិកាមិនមែនកម្មវិធី** ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ការរៀបចំគម្រោងឥណទានចំណាយថវិកាត្រូវផ្អែកលើតម្រូវការចំណាយជាក់ស្តែង និង ដោយផ្ទាល់ សម្រាប់អនុវត្តសកម្មភាពការងាររបស់

អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីសម្រេចគោលដៅនៃយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយ ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ *សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២២- គ្រប់ក្រសួង **ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត** ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ គម្រោងចំណាយចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងដោយលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា(ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវមានការវិភាគលម្អិតល្អន់អំពីតម្រូវការចំណាយទៅតាមសកម្មភាពជាអាទិភាព និងត្រូវមានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់អំពីភាព-ចាំបាច់នៃចំណាយ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិកដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបទៅនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ២០១៤ និងប៉ាន់ស្មានឆ្នាំ២០១៥ និង ដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២៣- លើមូលដ្ឋាននៃតម្រូវការចំណាយដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកាក្នុងការរៀបចំគម្រោងចំណាយសម្រាប់ឆ្នាំ២០១៦ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ព្រមទាំងព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវជានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួនដោយអនុលោមទៅតាម **គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)** ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ២០១៥សិន ពោលគឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៥។ក្នុងពេលរង់ចាំគោលការណ៍តម្លើងបៀវត្សមន្ត្រីរាជការឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានគ្រោងថវិកាជាកញ្ចប់រួមសម្រាប់វិស័យនីមួយៗដូចមានចែងនៅក្នុងផ្នែកស្តីពីក្របខណ្ឌចំណាយថវិកាឆ្នាំ២០១៦ ខាងលើ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវផ្អែកលើគោលការណ៍បែងចែកដោយក្រសួងមុខងារសាធារណៈ បន្ទាប់ពីទទួលបានគោល-ការណ៍ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ពោលគឺចំនួនក្របខណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខណ្ឌរដ្ឋ និងមរណភាព**ដែលត្រូវកាត់ចេញពីអង្គភាពសាមី និងមិនត្រូវគ្រោងថវិកាទេ។ ចំពោះការឡើងឋានៈ និង កាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។ ចំពោះបុគ្គលិកជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត ក្រសួងមុខងារសាធារណៈត្រូវស្នើសុំគោល-ការណ៍ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ជ្រើសរើស និងប្រើប្រាស់។

• **ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភកធន)** ត្រូវគ្រោងក្នុងកម្រិតអតិបរមា ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដោយឈរលើគោលការណ៍ដូចខាងក្រោម៖

- **បន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការដោយ**ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងចំណាយដោយផ្អែកលើបរិមាណជាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៤កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ២០១៥នេះ និង ដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយជៀសវាងការបង្កើនបរិមាណជាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនឹងនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញឧបករណ៍សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការបោះពុម្ពប្រណិត ការជួសជុលធំ សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធិកអធម និងបេសកកម្មក្នុងនិងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា សេវាទូរគមនាគមន៍ អគ្គិសនី និង ទឹកជាដើម
- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវពិនិត្យឡើងវិញ ហើយកាត់ចេញនូវមុខចំណាយដែលមានតម្រូវការតែសម្រាប់ឆ្នាំ២០១៥ តែលែងត្រូវការនៅក្នុងឆ្នាំ២០១៦ ឬ ដែលសកម្មភាពការងារត្រូវបានបញ្ចប់
- ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការរីកដឡើងវិញជាស្វ័យប្រវត្តិឡើយ គឺលុះត្រាតែមាន**សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី**ដែលត្រូវអនុវត្ត ហើយដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ហើយមានយុត្តិការអំពីភាពចាំបាច់ និងបន្ទាន់។

• ក្នុងករណីមានគោលនយោបាយ ឬ/និងសកម្មភាពការងារថ្មី ដែលមានតម្រូវការថវិកាលើសពីកញ្ចប់ឥណទានថវិកាឆ្នាំ២០១៥ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវលើកគម្រោងចំណាយនោះដោយឡែក រួមទាំងគម្រោងចំណាយសម្រាប់អាជ្ញាធរ គណៈកម្មការ ឧត្តមក្រុមប្រឹក្សា ក្រុមប្រឹក្សា និង អង្គភាពដែលចំណុះឱ្យក្រសួង ស្ថាប័ន ដោយបង្ហាញទឡ្ហីករណ៍អំពីភាពចាំបាច់ អាទិភាពខ្ពស់ និងផ្អែកលើទំហំ បរិមាណ និងថ្លៃ ដែលអាចទទួលយកបាន។ ទន្ទឹមនឹងនេះដែរ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវខិតខំធ្វើវិចារណកម្មចំណាយក្នុងរង្វង់ក្របខណ្ឌថវិការបស់ខ្លួន និងខិតខំលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រោងថវិកាឱ្យបានត្រឹមត្រូវ ទាំងបរិមាណ និងតម្លៃឯកតា ជាមុនសិន មុននឹងទទួលបានការពិចារណាលើការបន្ថែមថវិកា។

• ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំថវិកា ពិសេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អនុវត្តសកម្មភាពការងារថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃ

ឥណទានថវិកាឆ្នាំ២០១៥ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង តាមជំពូកនីមួយៗ ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់ត្រឹមកម្រិតឆ្នាំ២០១៥។ ប៉ុន្តែការរៀបចំគម្រោងចំណាយលម្អិត តម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោងថវិកា ព្រោះ ***ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តភាពឥណទានថវិកាផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចនឹងត្រូវអនុញ្ញាតឱ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី២ សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី និងចាប់ពីត្រីមាសទី៣ សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាមិនមែនកម្មវិធី។***

២៤- ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវធ្វើការ **គណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក** រួមមាន ជំពូក៦០ ជំពូក៦១ ជំពូក៦២ និងជំពូក ៦៥ ដោយផ្អែកលើមូលដ្ឋានពីរដូចខាងក្រោម៖

- *កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមាន ការចំណាយសម្ភារផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជាសម្ភារការិយាល័យ ការបោះពុម្ព និងទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួង ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។
- *កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ការចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និង មានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

២៥- ទន្ទឹមនឹងត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៥ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ក្នុងការរៀបចំថវិកាឆ្នាំ២០១៦ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ផ្ទៃក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយ ទៅកម្មវិធីអនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត មានការប្រែប្រួល។

- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

២៦- ក្នុងគោលដៅសមាហរណកម្មថវិការបស់ក្រសួង ស្ថាប័ន រវាងសកម្មភាពការងាររដ្ឋបាលកណ្តាល និង មន្ទីរជំនាញរាជធានី ខេត្ត និង អង្គភាពក្រោមឱវាទ ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយរបស់ខ្លួន ក្រសួង ស្ថាប័ននីមួយៗ គួររៀបចំជាបណ្តើរៗឱ្យមានជាគោលការណ៍ និងវិធីសាស្ត្រវិភាជថវិកាច្បាស់លាស់ ជាពិសេសនិយាមចំណាយសមស្របសម្រាប់អង្គភាពក្រោមឱវាទ និងមន្ទីរជំនាញរាជធានី ខេត្ត ដែលជាខ្សែបណ្តោយ អាចប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើនសុក្រឹតភាពនៃការគ្រោងចំណាយប្រចាំឆ្នាំ និងអាចឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រើប្រាស់ជាមូលដ្ឋានក្នុងការវិនិច្ឆ័យលើអំណះអំណាងនៃតម្រូវការថវិកា និងធ្វើការចរចាកំណត់កញ្ចប់ថវិកា ដើម្បីលើកកម្ពស់ ប្រសិទ្ធភាពនៃការវិភាជថវិកា។

២៧- ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។

## គ- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៦

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ជាមួយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ចាប់ពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៥

**ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៥ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបានមុន ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥។**

២៩- **ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកាឆ្នាំ២០១៦** ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់ការពិភាក្សាកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ ដូច្នេះក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន ឬ មន្ទីរជំនាញរាជធានី ខេត្តនោះឱ្យបានទាន់ពេលវេលាដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ២០១៥ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើសម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លានរៀល។

## IV- សេចក្តីសន្និដ្ឋាន

៣០- ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់នូវក្របខណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេស ក្នុងការគ្រោងចំណូល និងចំណាយចាំបាច់ សម្រាប់ជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណា សម្រេចឱ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែងប្រកប ដោយ ចីរភាពក្នុងរង្វង់ប្រមាណ ៧% និង ការកាត់បន្ថយភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមរមនាសង្គម និងសុខុមាលភាពប្រជាជន។

៣១- ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញដោយសារាចរនេះ អាចអនុវត្តឱ្យសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ពិសេស ត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតនៅក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយ

សារាចរណែនាំនេះ។ ទន្ទឹមនឹងនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ដែលជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាជន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣២- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៥** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតជំនាញ និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័នទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ( នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៦ សរណន

## សារាចរណែនាំ
## ស្ដីពី
## ការប្រារព្ធពិធីកាន់ទុក្ខ
## សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា
## និងជាប្រធានគណបក្សប្រជាជនកម្ពុជា

ដោយ **សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា ដែលក្នុងមួយជីវិតរបស់**សម្ដេច** **សម្ដេច**បានលះបង់កំលាំងកាយ និងកំលាំងចិត្តក្នុងការតស៊ូរំដោះជាតិ មាតុភូមិ ពិសេសការតស៊ូរំដោះប្រទេសជាតិឱ្យរួចចាកផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមនាឆ្នាំ១៩៧៩ និងបន្តចូលរួមដឹកនាំ កសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យមានការរីកចម្រើន រុងរឿងដូចបច្ចុប្បន្ននេះ ហើយបានទទួលមរណភាពនៅថ្ងៃ ច័ន្ទ ០៧ រោច ខែជេស្ឋ ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ ត្រូវនឹងថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ វេលាម៉ោង ១៥ : ៤៥ នាទី ក្នុងជន្មាយុ ៨៣ឆ្នាំ ដោយរោគាពាធ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដូចតទៅ :

១- ប្រកាសថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៥ ជាថ្ងៃកាន់ទុក្ខជាផ្លូវការ ។

២- គ្រប់ក្រសួង ស្ថាប័ន សាលារៀន មន្ទីរពេទ្យរបស់រដ្ឋ ឯកជនទាំងអស់ និងមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រប់ទីវត្តអារាម ព្រមទាំងប្រជាជនទូទាំងប្រទេស ត្រូវបង្ហូតទង់ជាតិត្រឹមមួយភាគបីនៃដងទង់ជាតិចាប់ពីលើ នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៥ ។

៣- គ្រប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ជាតិ និងឯកជនទាំងអស់ ត្រូវផ្អាកការសំដែង និងការចាក់ផ្សាយនូវទស្សនីយភាពផ្សេងៗដែលមានលក្ខណៈសប្បាយគគ្រឹកគគ្រេង នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៥ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងជនរួមជាតិទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាកិច្ចចូលរួមមរណៈទុក្ខដ៏ក្រៀមក្រំបំផុតនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៦៣ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៥
## របស់ក្រសួងការពារជាតិ

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៅក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ខែវិច្ឆិកា ឆ្នាំ១៩៩៥ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុញ្ញាតបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ", ជំពូក៦១ នៅក្រសួងការពារជាតិសម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ ៥ នៃប្រកាសលេខ១៩៣៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍.ទៀ-បាញ់**

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមុខងារសាធារណៈ

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-សាលារាជធានី ខេត្ត

-ដូចប្រការ ៤

-រាជកិច្ច

-ឯកសារ

-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# តារាងឧបសម្ព័ន្ធ

## រដ្ឋទេយ្យបុរេប្រទានថវិកាឆ្នាំ២០១៥

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន ០១ដុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ដុំ | ៦=៣/២ |
| | | | **សរុបរួម** | **277,952,000,000** | **12,185,640,000** | **5,376,000,000** | **6,809,640,000** | **896,000,000** | **44%** |
| **60** | | | **ការទិញ** | **274,442,000,000** | **8,675,920,000** | **2,016,300,000** | **6,659,620,000** | **336,050,000** | **23%** |
| | 6001 | | សំភារៈផ្គត់ផ្គង់ថែទាំ | 111,495,000,000 | | | | | |
| | | 60012 | សំភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 2,040,000,000 | | | | | |
| | | 60014 | សំភារៈផ្គត់ផ្គង់សម្រាប់ថែទាំសំភារៈឧបករណ៍ | 8,695,000,000 | | | | | |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 100,760,000,000 | | | | | |
| | 6002 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 816,000,000 | 815,960,000 | 575,940,000 | 240,020,000 | 95,990,000 | 71% |
| | | 60021 | សំភារៈការិយាល័យនិងការបោះពុម្ព | 800,000,000 | 800,000,000 | 559,980,000 | 240,020,000 | 93,330,000 | 70% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 16,000,000 | 15,960,000 | 15,960,000 | 0 | 2,660,000 | 100% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 89,299,000,000 | | | | | |
| | | 60031 | ស្បៀង | 89,299,000,000 | | | | | |
| | 6004 | | សំលៀកបំពាក់និងការតុបតែង | 52,272,000,000 | | | | | |
| | | 60041 | ឯកសណ្ឋាន | 36,614,000,000 | | | | | |
| | | 60048 | សំលៀកបំពាក់និងការតុបតែងផ្សេងៗ | 15,658,000,000 | | | | | |
| | 6005 | | សំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខារ | 5,960,000,000 | 5,159,960,000 | 480,420,000 | 4,679,540,000 | 80,070,000 | 9% |
| | | 60051 | សំភារៈនិងបរិក្ខារបច្ចេកទេស | 5,000,000,000 | 5,000,000,000 | 320,460,000 | 4,679,540,000 | 53,410,000 | 6% |
| | | 60052 | សង្ហារឹម | 160,000,000 | 159,960,000 | 159,960,000 | 0 | 26,660,000 | 100% |
| | | 60053 | សំភារៈប្រើប្រាស់ | 800,000,000 | | | | | |
| | 6006 | | ថាមពលនិងទឹក | 11,900,000,000 | | | | | |
| | | 60061 | អគ្គិសនី | 10,350,000,000 | | | | | |
| | | 60062 | ទឹក | 1,550,000,000 | | | | | |
| | 6007 | | សំភារៈបរិក្ខារថែទាំសុខភាព | 1,050,000,000 | 1,050,000,000 | 159,960,000 | 890,040,000 | 26,660,000 | 15% |
| | | 60078 | សំភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ | 1,050,000,000 | 1,050,000,000 | 159,960,000 | 890,040,000 | 26,660,000 | 15% |
| | 6098 | | សំភារៈផ្គត់ផ្គង់ផ្សេងៗ | 1,650,000,000 | 1,650,000,000 | 799,980,000 | 850,020,000 | 133,330,000 | 48% |
| **61** | | | **សេវាកម្ម** | **3,510,000,000** | **3,509,720,000** | **3,359,700,000** | **150,020,000** | **559,950,000** | **96%** |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 500,000,000 | 499,980,000 | 499,980,000 | 0 | 83,330,000 | 100% |
| | 6105 | | ការថែទាំនិងជួសជុល | 1,150,000,000 | 1,149,920,000 | 999,900,000 | 150,020,000 | 166,650,000 | 87% |
| | | 61052 | ការថែទាំជួសជុលអគារផ្សេងៗ និងប្រាសាទ | 160,000,000 | 159,960,000 | 159,960,000 | 0 | 26,660,000 | 100% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 230,000,000 | 230,000,000 | 79,980,000 | 150,020,000 | 13,330,000 | 35% |
| | | 61056 | ការថែទាំនិងជួសជុលផ្សេងៗ | 760,000,000 | 759,960,000 | 759,960,000 | 0 | 126,660,000 | 100% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 840,000,000 | 839,940,000 | 839,940,000 | 0 | 139,990,000 | 100% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 180,000,000 | 180,000,000 | 180,000,000 | 0 | 30,000,000 | 100% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 250,000,000 | 249,960,000 | 249,960,000 | 0 | 41,660,000 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 350,000,000 | 349,980,000 | 349,980,000 | 0 | 58,330,000 | 100% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 60,000,000 | 60,000,000 | 60,000,000 | 0 | 10,000,000 | 100% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 300,000,000 | 299,940,000 | 299,940,000 | 0 | 49,990,000 | 100% |

-តទៅទំព័រទី ២-

-ទំព័រទី ២-

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន ០១ដុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ដុំ | ៦=៣/២ |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 50,000,000 | 49,980,000 | 49,980,000 | 0 | 8,330,000 | 100% |
| | | 61122 | សោហ៊ុយបេសកកម្ម | 250,000,000 | 249,960,000 | 249,960,000 | 0 | 41,660,000 | 100% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 520,000,000 | 519,960,000.00 | 519,960,000 | 0 | 86,660,000 | 100% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 160,000,000 | 159,960,000 | 159,960,000 | 0 | 26,660,000 | 100% |
| | | 61132 | សោហ៊ុយបេសកកម្ម | 240,000,000 | 240,000,000 | 240,000,000 | 0 | 40,000,000 | 100% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 120,000,000 | 120,000,000 | 120,000,000 | 0 | 20,000,000 | 100% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 200,000,000 | 199,980,000 | 199,980,000 | 0 | 33,330,000 | 100% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 200,000,000 | 199,980,000 | 199,980,000 | 0 | 33,330,000 | 100% |

លេខ:

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៥

រ. អគ្គនាយក

**អគ្គនាយកដ្ឋានរតនាគារជាតិ**

អគ្គនាយករង

មិញ បានសុវណ្ណអាណិច្ចាសីលា

លេខ:

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៥

**អគ្គនាយក**

**អគ្គនាយកដ្ឋានថវិកា**

បណ្ឌិត. ញឹម ខេមរា

លេខ: ០៧០/១៥ គសហ

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៥

**អគ្គនាយកដ្ឋានគណនេយ្យសាធារណៈ**

នាយឧត្តមសេនីយ៍.ស៊ុំ_សំណាង

ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៥

**រដ្ឋលេខាធិការប្រធាន**

ឧត្តមសេនីយ៍ទោ.ញាណ_ហាន

បានឃើញ និងឯកភាព

ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

លេខ: ០១១/ឧ.ន.

២០១៥

បានឃើញ និងឯកភាព

ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍.ទៀ_បាញ់**

នាយឧត្តមសេនីយ៍.ម៉ឹង_សំផន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ ៥៣៣ សហវ.ប្រក

ប្រកាស

ស្តីពី

ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស
សម្រាប់មន្ត្រីនៃលេខាធិការដ្ឋាន របស់គណៈកម្មការមូលបត្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92 Sangkat Wat Phonm, Khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤
Phone : 855-23-724 664
ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Fax: 855-23-427 798

- បានឃើញប្រកាសលេខ ០០៣ គមក.ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីលក្ខន្តិកៈនៃមន្ត្រីរបស់គណៈកម្មការមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការមូលបត្រកម្ពុជា

## សម្រេច

**ប្រការ១.–**

ប្រកាសនេះ មានគោលដៅកំណត់អំពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស របស់មន្ត្រី នៃលក្ខន្តិកៈ របស់គណៈកម្មការមូលបត្រកម្ពុជា អនុលោមតាមមាត្រា២៥ នៃអនុក្រឹត្យលេខ ៩៧ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មការមូលបត្រកម្ពុជា។

**ប្រការ២.–**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស របស់មន្ត្រី នៃលក្ខន្តិកៈ របស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)។

**ប្រការ៣.–**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រី នៃលក្ខន្តិកៈ របស់ គ.ម.ក. ដែលបំពេញបេសកកម្មទាំងនៅក្នុង និងក្រៅប្រទេស ក្នុងក្របខណ្ឌនៃការបំពេញការងាររបស់គណៈកម្មការមូលបត្រកម្ពុជា។

**ប្រការ៤.–**

បេសកកម្ម សំដៅដល់ការបំពេញមុខងារ និងភារកិច្ចរបស់មន្ត្រី នៃលក្ខន្តិកៈ របស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) នៅក្រៅប្រទេស ឬនៅក្នុងប្រទេសដោយមានបម្លាស់ទីចេញពីក្នុងរង្វង់ដែនដី នៃរាជធានី ក្រុង ឬស្រុក ដែលសាមីខ្លួនបំពេញមុខងារជាប្រក្រតី។

ប្រាក់បេសកកម្ម រួមមានប្រាក់ហោប៉ៅ ប្រាក់ហូបចុក ប្រាក់ស្នាក់នៅ សោហ៊ុយធ្វើដំណើរ ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ និងប្រាក់ចំណាយផ្សេងៗ ដែលត្រូវកំណត់ និងផ្តល់ជូន ទៅតាមប្រភេទបេសកកម្មនីមួយៗ។ ប្រាក់ស្នាក់នៅ ត្រូវផ្តល់ជូនចំពោះបេសកកម្មដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់។

**ប្រការ៥.–**

ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់មន្ត្រី នៃលក្ខន្តិកៈរបស់ គ.ម.ក. ត្រូវកំណត់ដោយអនុលោមតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៦.–**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីកាលបរិច្ឆេទចូលជាធរមាន នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**ប្រការ៧.-**

ប្រកាសលេខ ០១០/១២ គមក/ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេសសម្រាប់មន្ត្រី-បុគ្គលិករបស់គណៈកម្មការមូលបត្រកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទគណៈកម្មការមូលបត្រកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.០១៥.១៨៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការបង្កើតមណ្ឌលដោះដូរមូលប្បទានបត្រ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង

* * * * * * * * * * * * * * * *

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៩.០១៣-១២៥ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យប្រើវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ
- យោងប្រកាសលេខ ធ៩.០១៥-០០៦ប្រក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥

## ស ម្រេ ច

**ប្រការ ១.~**

ប្រកាសនេះ មានគោលបំណងបង្កើតមណ្ឌលដោះដូរមូលប្បទានបត្រនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង ដើម្បីសម្រួលដល់ការទូទាត់ក្នុងខេត្ត និងឆ្លងខេត្ត ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ២.~**

មណ្ឌលដោះដូរមូលប្បទានបត្រសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង មានភារកិច្ច ដូចតទៅ:

ក)-ផ្តល់ទីតាំងជូនគ្រឹះស្ថានធនាគារដែលជាសមាជិក ដើម្បីធ្វើការដោះដូរមូលប្បទានបត្រជារូបវន្ត

ខ)-ផ្តល់កិច្ចសហការសម្របសម្រួលដល់សមាជិកនូវរាល់សំណូមពរចាំបាច់ពាក់ព័ន្ធនឹងការងារទូទាត់

គ)-បញ្ជូនទិន្នន័យឧបករណ៍ទូទាត់ទៅសភាផាត់ទាត់ជាតិ ដើម្បីផាត់ទាត់ និងទូទាត់

ឃ)-ទទួលព័ត៌មានអំពីលទ្ធផលនៃការផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់ពីសភាផាត់ទាត់ជាតិ

ង)-ផ្តល់របាយការណ៍សរុបជូនសមាជិកសម្រាប់ការផ្ទៀងផ្ទាត់ឧបករណ៍ទូទាត់ ។

**ប្រការ៣.~**

មណ្ឌលដោះដូរមូលប្បទានបត្រសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ធ៩.០១៣-១២៥ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យប្រើវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ និងប្រកាសលេខ ធ៩.០១៥-០០៦ប្រក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ។

**ប្រការ៤.~**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.~**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៦.~**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៥

**ទេសាភិបាល**

ជា.ចាន់តូ

**កន្លែងទទួល :**

- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អភិបាលខេត្តស្វាយរៀង
- គ្រប់ធនាគារសមាជិកសភាផាត់ទាត់ជាតិ

"ដើម្បីជ្រាបជាព័ត៌មាន"

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៥-១៨៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតមណ្ឌលដោះដូរមូលប្បទានបត្រ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ

* * * * * * * * * * * * * * * *

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៩.០១៣-១២៥ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យប្រើវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ
- យោងប្រកាសលេខ ធ៩.០១៥-០០៦ប្រក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងបង្កើតមណ្ឌលដោះដូរមូលប្បទានបត្រនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ ដើម្បីសម្រួលដល់ការទូទាត់ក្នុងខេត្ត និងឆ្លងខេត្ត ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ២.~**

មណ្ឌលដោះដូរមូលប្បទានបត្រសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ មានភារកិច្ច ដូចតទៅ:

ក)-ផ្តល់ទីតាំងជូនគ្រឹះស្ថានធនាគារដែលជាសមាជិក ដើម្បីធ្វើការដោះដូរមូលប្បទានបត្រជារូបវន្ត

ខ)-ផ្តល់កិច្ចសហការសម្របសម្រួលដល់សមាជិកនូវរាល់សំណួមពរចាំបាច់ពាក់ព័ន្ធនឹងការងារផាត់ទាត់

គ)-បញ្ជូនទិន្នន័យឧបករណ៍ទូទាត់ទៅសភាផាត់ទាត់ជាតិ ដើម្បីផាត់ទាត់ និងទូទាត់

ឃ)-ទទួលព័ត៌មានអំពីលទ្ធផលនៃការផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់ពីសភាផាត់ទាត់ជាតិ

ង)-ផ្តល់របាយការណ៍សរុបជូនសមាជិកសម្រាប់ការផ្ទៀងផ្ទាត់ឧបករណ៍ទូទាត់ ។

**ប្រការ៣.~**

មណ្ឌលដោះដូរមូលប្បទានបត្រសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ធ៩.០១៣-១២៥ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យប្រើវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ និងប្រកាសលេខ ធ៩.០១៥-០០៦ប្រក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ។

**ប្រការ៤.~**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.~**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៦.~**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៥

**ទេសាភិបាល**

ជា-ចាន់តូ

**__កន្លែងទទួល__** :

- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**__ចម្លងជូន__** :

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អភិបាលខេត្តបន្ទាយមានជ័យ
- គ្រប់ធនាគារសមាជិកសភាផាត់ទាត់ជាតិ

"ដើម្បីជ្រាបជាព័ត៌មាន"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*

លេខ ១៤៧ ពណ.ជសក.ប្រក

ភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធី ចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នសរកត/០៩១៣/៩០៣/ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់ឲ្យពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តន៍នូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់។


ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា  ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*  *Phone/Facsimile: (855)-23 866 469*

**ប្រការ ២.-**

ពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ត្រូវជាអ្នកចុះហត្ថលេខាលើពាក្យស្នើសុំចុះក្នុងបញ្ជីពាណិជ្ជកម្មនូវការកែប្រែក្រោយចុះបញ្ជី និងផ្តល់ឯកសារតម្រូវសម្រាប់តម្កល់ទៅឲ្យនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣.-**

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មផងដែរ ប្រសិនបើសហគ្រាស ក្រុមហ៊ុន មានការកែប្រែក្នុងដំណើរការអាជីវកម្មរបស់ខ្លួនដូចខាងក្រោម៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសារជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ ។
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត
- ការកែប្រែចិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនក្វ៉ុម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលច្បាប់អនុញ្ញាតឲ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន
- ការផ្ទេរ ឬលក់ភាគហ៊ុនទាំងឡាយដែលអនុញ្ញាតដោយច្បាប់ ។

**ប្រការ ៤.-**

ចំពោះការផ្ទេរ ឬលក់ភាគហ៊ុនដូចមានចែងក្នុងប្រការ ៣ ខាងលើ ដើម្បីធានាអះអាង និងទទួលខុសត្រូវលើការផ្ទេរ ឬលក់ភាគហ៊ុនថាពិតជាត្រឹមត្រូវ រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុនត្រូវមានការបញ្ជាក់ដូចខាងក្រោម៖

- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីមេធាវី ឬសារការី នៃព្រះរាជាណាចក្រកម្ពុជា
- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្រៅព្រះរាជាណាចក្រកម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីសារការី ឬអាជ្ញាធរ ដែលមានសមត្ថកិច្ច នៃប្រទេសដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនកំពុងរស់នៅ
- ក្នុងករណី ម្ចាស់ហ៊ុនដែលជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនរបស់ខ្លួនមិនត្រូវការការបញ្ជាក់ពីមេធាវី ឬសារការី នោះសាមីខ្លួនអាចមកចុះហត្ថលេខា និងផ្តិតមេដៃដោយផ្ទាល់នៅចំពោះមុខមន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

**ប្រការ ៥**.-

ឯកសារតម្រូវ ដែលត្រូវផ្តល់ជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោមៈ

- កំណត់ហេតុ និងសេចក្តីសម្រេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន (ច្បាប់ដើម) ចំនួន ០៣ ច្បាប់
- ពាក្យស្នើសុំធ្វើការកែប្រែនិងផ្លាស់ប្តូរ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
  (វិញ្ញានបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណី ក្រុមហ៊ុនធ្វើការកែប្រែនាមករណ៍ ប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន)
- ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណប៉ាតង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងរូបថតទំហំ ៤ x ៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ ( ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី )
- ច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង - ស្ថាប័នពាក់ព័ន្ធ " បើសិនជាមាន " ចំនួន ០៣ ច្បាប់

**ប្រការ ៦**.-

ប្រកាសលេខ ០៩៩MOC/SM2008 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីបែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧**.-

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

***ចម្លងជូន***

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
- *ក្រសួង-ស្ថាប័ន*
- *ដូចប្រការ ៧ "ដើម្បីអនុវត្ត"*
- *សាលារាជធានី-ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០១ ក.យ.សណន/១៥

# សេចក្តីណែនាំ
## ស្តីពី
## និរន្តរភាព ប្រសិទ្ធភាព និងសុខដុមនីយកម្ម នៃអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី

អនុលោមតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ក្រសួងយុត្តិធម៌បានរៀបចំបទដ្ឋានគតិយុត្តិក្រោមច្បាប់មួយចំនួន ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ ជាពិសេសអនុក្រឹត្យពាក់ព័ន្ធនឹងការរៀបចំអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី។

ដោយហេតុថាការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់សាលាដម្រះក្តី និងអង្គការអយ្យការអមសាលាដម្រះក្តី ជាការងារចាំបាច់ដែលត្រូវធានានិរន្តរភាព និងប្រសិទ្ធភាព ក្រសួងយុត្តិធម៌បានរៀបចំសំណើតែងតាំងប្រធានអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី ក៏បានធ្វើការណែនាំឲ្យប្រធានអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តីចូលកាន់តំណែងរួចរាល់។ ប៉ុន្តែកន្លងមកក្រសួងពិនិត្យឃើញថា អង្គភាពរដ្ឋបាលនៃសាលាដម្រះក្តីនៅពុំទាន់អាចរៀបចំ និងដំណើរការបានល្អនៅឡើយ ដែលធ្វើឲ្យមានការរាំងស្ទះដល់ប្រសិទ្ធភាពនៃការរៀបចំប្រព័ន្ធរដ្ឋបាលរបស់សាលាដម្រះក្តី ស្របតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

អាស្រ័យហេតុនេះ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និរន្តរភាព និងសុខដុមនីយកម្មនៃអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

១. រចនាសម្ព័ន្ធរបស់អង្គការតុលាការ និងអង្គការអយ្យការ ត្រូវរៀបចំឲ្យបានស្របតាមស្មារតីនៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឲ្យបានឆាប់រហ័ស។

២. ចាប់ពីមានការតែងតាំងប្រធានអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី ស្របតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ តំណែងនាយកក្រឡាបញ្ជីតុលាការ និងនាយកក្រឡាបញ្ជីអយ្យការ ពុំមានអត្ថិភាពទៀតទេ។

៣. គ្រប់នាយកក្រឡាបញ្ជី និង/ឬក្រឡាបញ្ជី ត្រូវផ្ទេរការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់សាលាដម្រះក្តី និងអង្គការអយ្យការអមសាលាដម្រះក្តី ដែលខ្លួនធ្លាប់ទទួលបន្ទុកពីមុន មកឲ្យប្រធានអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី ដើម្បីអនុវត្តឲ្យបានស្របតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

៤. ក្រឡាបញ្ជីដែលត្រូវបានតែងតាំង នៅក្នុងរចនាសម្ព័ន្ធរបស់អង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី នៅបន្តលក្ខន្តិកៈជាក្រឡាបញ្ជី ប៉ុន្តែមិនអាចបំពេញមុខងារក្រឡាបញ្ជី ដែលជាជំនួយដល់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងនីតិវិធីតុលាការ និងអយ្យការ (កាន់សំណុំរឿង) ឡើយ។

៥. ករណីអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ពុំមានមន្ត្រីគ្រប់គ្រាន់សម្រាប់ដំណើរការ ប្រធានសាលាជម្រះក្តីអាចស្នើសុំមកក្រសួង ដើម្បីចាត់តាំងក្រឡាបញ្ជីឲ្យជួយការងាររដ្ឋបាលជាបណ្តោះអាសន្នបាន។

៦. មន្ត្រីរដ្ឋបាល ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតទាំងអស់ ដែលបម្រើការងារនៅសាលាជម្រះក្តី ត្រូវដាក់ឲ្យស្ថិតក្រោមការសម្របសម្រួល និងគ្រប់គ្រងរបស់អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី។

៧. ចៅក្រម និងព្រះរាជអាជ្ញារង មិនអាចចាត់ចែងការងាររបស់អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីឡើយ។

៨. ប្រធានសាលាជម្រះក្តី ប្រធានអង្គការអយ្យការអមសាលាជម្រះក្តី និងប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ត្រូវបង្កើនកិច្ចសហការ និងសម្របសម្រួល ដើម្បីរៀបចំឲ្យអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីមានកិច្ចដំណើរការល្អ ហើយក្នុងករណីចាំបាច់ត្រូវរាយការណ៍មកក្រសួងយុត្តិធម៌។

ទទួលបានសេចក្តីណែនាំនេះ ប្រធានសាលាជម្រះក្តី ប្រធានអង្គការអយ្យការអមសាលាជម្រះក្តី ប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី និងអង្គភាពពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃទីចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ខែឧសភា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍានា

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ